# អត្ថបទព្រះធម៌

## ភាគ៤

### សំរាប់មនុស្សគ្រប់វ័យ



ដោយ

ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណា**

ព.ស.២៥៥៣ គ.ស.២០០៩

www.hoksavann.org

**ចែកជាធម្មទាន**

# ប្រវត្តិរូបសង្ខេប
# ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណា

៙៙៙❁៚៚៚

ប្រសូត ថ្ងៃ១០មីនា១៩៤០ នៅឃុំព្រៃកប្បាស ស្រុកព្រៃ-កប្បាស ខេត្តតាកែវ ប្រទេសកម្ពុជា, ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណា** ជាបុត្រទី៣ក្នុងបណ្តាបុត្រទាំង៥នាក់ បិតានាម **ហុក ហៃ** មាតានាម **សុខ យឹម**។ ព្រះជន្ម១៥ឆ្នាំ បានបួសជាសាមណេរ លុះព្រះជន្ម២១ឆ្នាំ បានបំពេញឧប-សម្បទាជាភិក្ខុ។ កាលប្រព្រឹត្តការណ៍ឆ្នាំ១៩៧៥ ព្រះអង្គបានភៀសខ្លួនទៅប្រទេសថៃ បន្ទាប់មកបានទៅរស់នៅទីក្រុងម៉ុងរេ-អាល់ ប្រទេសកាណាដា នៅថ្ងៃ២៣មេសា១៩៨១។

កាលពីកុមារភាព ព្រះអង្គបានសិក្សាអក្សរសាស្ត្រជាតិចប់បឋមសិក្សា។ ពេលចូលកាន់ផ្នួស ព្រះអង្គបានសិក្សាធម្មវិន័យទាំង៣ថ្នាក់ត្រីទោឯក បានសិក្សានៅពុទ្ធិកសិក្សា ជាប់ពុទ្ធិក-បឋមសិក្សា ពុទ្ធិកមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ និងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ។ ឆ្លៀតទៅរៀនអក្សរសាស្ត្រនិងមនុស្សសាស្ត្រនៅសាកលវិទ្យាល័យភ្នំពេញ។ ក្រៅពីសិក្សាគន្ថធុរៈ ព្រះអង្គបានប្រតិបត្តិវិបស្សនាធុរៈអស់ជាច្រើន

ឆ្នាំ។ នៅបរទេស ព្រះអង្គបានសិក្សាបន្តជាប់អនុបណ្ឌិត (Master's degree) ទីបំផុត ជាប់បណ្ឌិតទស្សនាវិជ្ជាផ្នែកព្រះពុទ្ធសាសនា (Doctor of Philosophy on Buddhism) នៅសាកលវិទ្យាល័យញូដែល្លី នៃប្រទេសឥណ្ឌា នៅថ្ងៃ២៨កុម្ភៈ ២០០៤។

នៅក្នុងប្រទេសក៏ដូចជានៅក្រៅប្រទេស ព្រះអង្គបានជួយសង្គមខ្មែរយ៉ាងច្រើនផ្នែកបញ្ញាស្មារតី ដោយវិធីទេសនាពន្យល់តាមមាគ៌ាព្រះពុទ្ធសាសនា។

# មាតិកាអត្ថបទ


| | |
|---|---|
| ១. ភាសារលត់ជាតិរលាយ | ១ |
| ២. ជុំវិញបញ្ហាការកែប្រែអក្សរសាស្ត្រខ្មែរ | ៥ |
| ៣. សិល្បៈអាចជាយានអប់រំសីលធម៌ | ១១ |
| ៤. កេរ្តិ៍ដំណែលបុព្វបុរសខ្មែរ | ២៣ |
| ៥. សាមគ្គីធម៌ | ២៨ |
| ៦. សុជីវធម៌ និង សីលធម៌ | ៣៣ |
| ៧. នាយកធម៌ ធម៌សំរាប់អ្នកដឹកនាំ | ៣៧ |
| ៨. ព្រះវេស្សន្តរជាគំរូដល់អ្នកប្រជាធិបតេយ្យសម័យទំនើប | ៤១ |
| ៩. ការមិនបៀតបៀនអ្នកដទៃដោយយកខ្លួនជាគ្រឿងឧបមា | ៤៥ |
| ១០. ទំរើខ្វះការពិចារណានាំឲ្យខូចប្រយោជន៍ | |
| - រឿងអ្នកចំការពីរនាក់ | |
| - រឿងសត្វភេពីរ | ៤៨ |
| ១១. ទោសនៃការលេងល្បែងស៊ីសង | ៥៣ |
| ១២. មនុស្សឆ្កួត៨ពួក | ៥៨ |
| ១៣. ការឆ្កួតនឹងស្រី | ៦២ |
| ១៤. ប្រយ័ត្នទេសចររួមភេទ | ៧១ |
| ១៥. បុណ្យនៃសេចក្តីស្រឡាញ់ | ៧៨ |
| ១៦. ស្ត្រីម្នាក់បានស្លាប់ទាំងទារកក្នុងផ្ទៃ | ៨៣ |
| ១៧. វាសនានៃស្ត្រីកម្មកររោចក្រខ្មែរ | ៨៨ |


---

# ១- ភាសារលត់ជាតិរលាយ

ពាក្យខ្មែរមួយឃ្លាពោលថា **ភាសារលត់ជាតិរលាយ**។ ពាក្យថា **ជាតិ** ប្រែថាកំណើតឬពូជអម្បូរជាតិសាសន៍ដែលកើតតៗគ្នាមកពីជំនាន់មួយទៅជំនាន់មួយបន្តពីបុព្វបុរសរបស់ខ្លួន។ ជាតិនីមួយៗមានលក្ខណៈពិសេសរបស់ខ្លួន ដូចជាតិខ្មែរមានលក្ខណៈពិសេសជាខ្មែរជាដើម។លក្ខណៈនៃជាតិនីមួយៗសំគាល់នូវរូបរាងកាយ ពណ៌សម្បុរ ចិត្តគំនិតភាសានិយាយអក្សរសរសេរ ប្រពៃណីទំនៀមទម្លាប់ជំនឿសាសនាជាដើម។ចំពោះជនជាតិខ្មែរបានកើតជាប្រជាជាតិមួយមានអារ្យធម៌ដ៏ខ្ពង់ខ្ពស់ដែលមានភាសាប្រពៃណីទំនៀមទម្លាប់សាសនារបស់ខ្លួនរាប់ពាន់ឆ្នាំមកហើយ ដែលអ្នកប្រាជ្ញប្រវត្តិសាស្រ្តបានពោលថា ប្រទេសកម្ពុជានិងប្រជាជាតិខ្មែរបានកើតជាប្រទេសតាំងពីសតវត្សរ៍ទី១នៃគ.ស. ជាពិសេសមានអារ្យធម៌រុងរឿងបំផុត គឺនៅសម័យមហានគរ មានទឹកដីធំទូលំទូលាយ មានអធិបតេយ្យគ្រប់គ្រងជាតិដោយខ្លួនឯង មានមនោគមវិជ្ជាជាតិពិតប្រាកដនៅអាស៊ីភាគអគ្នេយ៍ ហើយបានជះឥទ្ធិពលរបស់ខ្លួនទៅលើប្រទេសជិតខាងទៀតផង។

ពាក្យថា **ភាសារលត់ជាតិរលាយ** បានសេចក្ដីថា គេសំគាល់ជាតិនីមួយៗ ដោយសំដីឬភាសានិយាយចេញមកដូចពាក្យខ្មែរមួយឃ្លាទៀតពោលថា **សំដីសជាតិ មារយាទស ពូជ**។ ទោះបីបរទេសរៀនភាសាខ្មែរ ក៏និយាយចេញមកមិនដូចខ្មែរនិយាយខ្មែរដែរ សំនៀងមានលក្ខណៈខុសគ្នា ដោយនៅជាប់សំនៀងភាសាកំណើតរបស់ខ្លួន។ បើភាសាកំណើតបាត់បង់ហើយ ជាតិនោះឯងគ្មានអ្វីជាចំណងមូលដ្ឋានដែលបញ្ជាក់ថា ជាជាតិពន្ធមានកំណើតជាមួយគ្នាតាំងពីដើមមក បើពុំមានភាសាសំរាប់ជាតិទេ គេពុំអាចប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកបានឡើយ ព្រោះភាសាជាសំដីសំដែងចេញនូវចិត្តគំនិតគោលបំណងឲ្យយល់គ្នាទៅវិញទៅមក។ គេចាត់ទុកភាសាកំណើតរបស់ខ្លួនជាភាសាទី១ដែលត្រូវតែចេះសំរាប់ជាតិខ្លួន ឯភាសាដទៃទៀតចាត់ជាភាសាទី២ឬទី៣ដូចជាភាសាអន្តរជាតិសំរាប់ប្រាស្រ័យទាក់ទងជាតិដទៃទៀត។ កូនចៅជាតំណតមកដើម្បីឲ្យពួកគេស្រឡាញ់ហើយថែរក្សាប្រពៃណីទំនៀមទម្លាប់របស់ជាតិខ្លួន លុះត្រាតែបានស្ដាប់មាតាបិតាជីដូនជីតានិយាយប្រាប់និងបានអានសៀវភៅជាឯកសារ នេះដោយចេះភាសានិយាយនិងភាសាសរសេរនេះឯង។ ភាសានិយាយនេះសំខាន់

សំរាប់ឲ្យមនុស្សយល់សេចក្ដីនិងអនុវត្តតាមនូវអ្វីមួយ។ ចំណែកភាសាកាយវិការដែលសព្វថ្ងៃគេពន្យល់មនុស្សថ្លង់ ពុំអាចយល់ឲ្យអស់សេចក្ដីហើយឲ្យត្រឹមត្រូវដូចភាសានិយាយឡើយ។ ទោះបីអ្នកខ្លះទៅនៅប្រទេសដទៃហើយយកសញ្ជាតិមួយទៀត ក៏នៅតែមានលក្ខណៈអត្តសញ្ញាណដើមរបស់ខ្លួន ឲ្យតែនៅចេះភាសាកំណើតរបស់ខ្លួន។

តាមការសង្កេត ជាតិរលាយពុំមែនត្រឹមតែភាសារលត់ទេ គឺត្រូវមានការបាត់បង់ទំនៀមទម្លាប់ប្រពៃណីរបស់ជាតិផ្សេងៗទៀត។ ការបាត់បង់ភាសាគ្រាន់តែទុកជាមូលដ្ឋានចំបងដែលធ្វើឲ្យជាតិរលាយប៉ុណ្ណោះ។

ចំពោះប្រទេសកម្ពុជាដែលបានឆ្លងកាត់វិបត្តិនយោបាយដ៏យូរនៅពេលនេះ ដើម្បីឲ្យអក្សរសាស្ត្រជាតិលូតលាស់ឡើងវិញឲ្យឆាប់រហ័ស រាជរដ្ឋាភិបាលគួរផ្ដល់ថវិកាឲ្យបានច្រើនទៅក្រសួងអប់រំ ដើម្បីឲ្យក្រសួងនេះមានលទ្ធភាពផ្ដល់បៀវត្សរ៍ឲ្យគ្រូនិងសាស្ត្រចារ្យឲ្យបានសមរម្យនិងរៀបចំកម្មវិធីសិក្សាឲ្យមានប្រសិទ្ធិភាព។ កូនខ្មែរទាំងអស់ត្រូវតែចូលសាលារៀន ត្រូវតែចេះអក្សរទាំងអស់គ្នា ដោយហោចត្រូវតែសិក្សាឲ្យចប់បឋមសិក្សា។ ត្រូវបំបាត់អនក្ខរជន គឺជនដែលមិនចេះអក្សរដោយ

បង្កើតកម្មវិធីបង្រៀនមនុស្សចាស់ដែលមិនចេះអក្សរ។ ត្រូវឲ្យតម្លៃអ្នកនិពន្ធខ្មែរ ដោយជម្រុញលើកទឹកចិត្តនិងផ្តល់មធ្យោបាយងាយស្រួលផ្សេងៗផ្តល់ថវិកាជាដើម។ ដើម្បីឲ្យស្នាដៃនិពន្ធបានល្អតាមលក្ខណៈជាតិ ត្រូវបង្កើតការសិក្សាខាងវិជ្ជានិពន្ធខ្មែរ។ ត្រូវបង្កើតការសិក្សាសិល្បៈគ្រប់ផ្នែករបស់ជាតិឲ្យខ្លាំងថែមទៀត ហើយទប់ទល់វប្បធម៌អាសអាភាសរបស់បរទេសកុំឲ្យជ្រៀតចូលក្នុងវប្បធម៌ខ្មែរ។ មួយផ្នែកទៀត គប្បីពង្រីកពុទ្ធិកសិក្សា គឺការសិក្សាផ្នែកព្រះសង្ឃសមណសិស្សនិងសមណនិស្សិតឲ្យបានលូតលាស់ថែមទៀត ដើម្បីជួយផ្លូវអាណាចក្រនៃប្រទេសកម្ពុជាឲ្យដើរតាមផ្លូវធម៌ គឺមាគ៌ាសន្តិវិធីគ្រប់ដំណោះស្រាយបញ្ហាជាតិ។

ចំពោះជនជាតិខ្មែរនៅបរទេស បើចង់នៅលក្ខណៈជាខ្មែរក្រៅពីថែរក្សាប្រពៃណីទំនៀមទម្លាប់និងព្រះពុទ្ធសាសនា គួរមាតាបិតាគ្រប់គ្រួសារជួយណែនាំកូនចៅឲ្យនិយាយខ្មែរក្នុងគ្រួសារ ហើយនាំពួកគេមកវត្តដើម្បីសុំព្រះសង្ឃឲ្យជួយអប់រំសីលធម៌ព្រះពុទ្ធសាសនានិងបង្រៀនអក្សរខ្មែរ។

៚៚៚

# ២- ជុំវិញបញ្ហា
# ការកែប្រែអក្សរសាស្ត្រខ្មែរ

គ្រប់ជាតិសាសន៍ក្នុងលោកតែងមានអក្សរសាស្ត្រ គឺភាសានិយាយនិងភាសាសរសេរសំរាប់ទាក់ទងគ្នាទៅវិញទៅមកនិងសំរាប់ផ្ទុកមុខវិជ្ជាផ្សេងៗ។ យ៉ាងណាមិញ ប្រទេសកម្ពុជាក៏មានអក្សរសាស្ត្ររបស់ខ្លួនដ៏រុងរឿងជាច្រើនសតវត្សរ៍មកហើយ។ បច្ចុប្បន្ននេះ ដោយសារតែប្រទេសកម្ពុជាមានវិបត្តិផ្ទៃក្នុងជាច្រើនទសវត្សរ៍ ពុំអាចរៀបចំអក្សរសាស្ត្ររបស់ខ្លួនឲ្យចំរើនលូតលាស់ឡើយ។ មិនតែប៉ុណ្ណោះ នៅពេលដែលប្រទេសកម្ពុជាមានសន្តិភាពឡើងវិញ មានខ្មែរមួយក្រុមតូចបានលួចកែប្រែអក្សរសាស្ត្រខ្មែរផ្នែកអក្សរសរសេរជាច្រើនពាក្យដោយផ្អែកលើមូលដ្ឋានពុំសមហេតុផល។ ធម្មតាអក្សរជាតិណាក៏ដូចជាតិណា ពុំអាចមានពាក្យគ្រប់គ្រាន់សំរាប់ប្រើការឡើយ តែងតែមានខ្ចីពីពាក្យនៃភាសាដទៃមកប្រើបន្ថែម។ ដូចភាសាបារាំងនិងភាសាអង់គ្លេសមានខ្ចីពាក្យនៃភាសាក្រិកនិងភាសាឡាតាំងជាច្រើន។ ពាក្យកម្ចីទាំងនោះ គេរក្សាទុករូបរាងដើម គ្រាន់តែសម្រួលសម្លេងឲ្យស្របតាមភាសាខ្លួនប៉ុណ្ណោះ។ ដូចគ្នានេះ

ដែរ ពាក្យខ្មែរមានខ្ចីពាក្យពីភាសាសំស្ក្រឹតនិងបាលីជាច្រើន ប៉ុន្តែបង្វែសម្លេងឲ្យស្របតាមសម្លេងភាសាខ្មែរ។ ដើម្បីចេះភាសាខ្មែរច្បាស់លាស់ គេត្រូវតែសិក្សាភាសាសំស្ក្រឹតនិងភាសាបាលីផង ព្រោះមានពាក្យខ្លះមានឫសគល់ចេញមកពីភាសាសំស្ក្រឹតនិងភាសាបាលី។ ព្រះសង្ឃជាសមណសិស្សនិងសមណនិស្សិតសិក្សាភាសាបាលីតាំងពីពុទ្ធិកបឋមសិក្សា និងសិក្សាភាសាសំស្ក្រឹតតាំងពីពុទ្ធិកមធ្យមសិក្សារហូតពុទ្ធិកឧត្តមសិក្សាផ្នែកបរិញ្ញាប័ត្រ។ ប៉ុន្តែគួរឲ្យស្តាយ មានបញ្ញវ័ន្តខ្មែរខ្លះដែលមានចំណេះច្រើនខាងផ្លូវលោកពុំបានដឹងជម្រៅនៃភាសាខ្មែរហ៊ានកែប្រែពាក្យខ្មែរខ្លះដែលខ្មែរធ្លាប់ប្រើជាយូរមកហើយ។ កាលមុនឆ្នាំ១៩៧០ មានបញ្ញវ័ន្តខ្មែរដែលមានចំណេះខាងផ្លូវលោកម្នាក់មានបំណងកែប្រែអក្សរសាស្ត្រខ្មែរ បញ្ញវ័ន្តខ្មែរនោះឈ្មោះលោកកេងវ៉ាន់សាក់។ នៅពេលដែលសម្តេចព្រះសង្ឃរាជជួនណាតប្រជុំអក្សរសាស្ត្រ ហើយគេយកមកចាក់ផ្សាយក្នុងវិទ្យុជាតិ សម្តេចព្រះសង្ឃរាជបានចោទទៅលើអ្នកដែលចង់កែប្រែអក្សរសាស្ត្រថា ជាមេក្រមីអក្សរសាស្ត្រ។ អ្នកដែលសម្តេចព្រះសង្ឃរាជចោទនោះ គឺលោកកេងវ៉ាន់សាក់នេះឯង ព្រោះលោកកេងវ៉ាន់សាក់នេះធ្លាប់បានពន្យល់ព្រះសង្ឃ

សមណនិស្សិត ហើយពោលអំពីបំណងរបស់គាត់ក្នុងការកែប្រែនេះ ហើយបានសរសេរពាក្យខ្លះដែលគាត់ចង់កែប្រែប្រាប់សមណនិស្សិត ហើយសមណនិស្សិតយកមកទូលសម្តេចព្រះរាជជួនណាត។ ដូច្នេះ មេក្រមីអក្សរសាស្ត្រ គឺលោកកេងវ៉ាន់សាក់នេះឯង។ មានពាក្យខ្មែរខ្លះ សរសេរតាមការពន្យល់របស់លោកកេងវ៉ាន់សាក់ដែលផ្ទុយអំពីវចនានុក្រមសម្តេចជួនណាត។ អក្សរសាស្ត្រដែលមានការអភិវឌ្ឍន៍នោះ គឺគេរក្សាទុកនូវពាក្យដែលមានហើយ គេពុំកែប្រែទេ ប៉ុន្តែគេបង្កើតពាក្យថ្មីៗទៀតដែលពុំទាន់មានឲ្យស្របតាមការចំរើនលូតលាស់នៃវិទ្យាសាស្ត្របច្ចេកទេសនិងវិជ្ជាផ្សេងៗទៀត។ ពាក្យខ្មែរដែលធ្លាប់សរសេរមកហើយ បានយល់ន័យរួចហើយ មិនត្រូវកែប្រែទេ។ ពាក្យខ្មែរដែលខ្ចីមកពីភាសាសំស្ក្រឹតនិងបាលីមានន័យគ្រប់គ្រាន់នៅក្នុងពាក្យនោះ បើសរសេរជាខ្មែរសុទ្ធត្រូវប្រើសេចក្តីវែងទើបស្តាប់សេចក្តីបាន។ មានកំហុសធំណាស់ដែលគេព្រហើនកាត់ពាក្យខ្លះដែលចេញពីបាលីនិងសំស្ក្រឹត ហើយគេសរសេរអក្សរផ្សេងឲ្យមានសម្លេងដូចគ្នា។ ការសរសេរបែបនេះ ជាការបំបាត់ឫសគល់របស់ពាក្យ ហើយមានន័យផ្សេងពីពាក្យមុន។ ថ្ងៃក្រោយ បើគេស្រាវជ្រាវ ពុំដឹងថា ពាក្យនោះចេញមកពីណា

ជាពាក្យខ្មែរសុទ្ធឬចេញមកពីភាសាណាទេ។ គេពុំត្រូវគិតថាការសរសេរពាក្យខ្មែរសុទ្ធ ទើបជាអ្នកជាតិនិយមនោះទេ ព្រោះពាក្យខ្មែរខ្លះ ដែលចេញពីបាលីនិងសំស្ក្រឹតក្លាយជាភាសាខ្មែររួចទៅហើយ។ មានអ្នកខ្លះ វែកញែកអក្សរសាស្ត្រមានន័យទៅរកនយោបាយ ពុំវែកញែកទៅតាមការពិតតាមលក្ខណៈវិទ្យាសាស្ត្រទេ។ ការបង្កើតពាក្យថ្មី បើប្រើភាសាខ្មែរសុទ្ធវែងពេក ទើបគេក្រឡេកមើលភាសាបាលីនិងសំស្ក្រឹតអាចមានពាក្យខ្លី តែមានន័យគ្រប់គ្រាន់ ដោយគ្រាន់តែបង្វែរសម្លេងឲ្យស្រប តាមសម្លេងភាសាខ្មែរប៉ុណ្ណោះ។

សម័យអាណានិគមនិយមបារាំងចង់កែប្រែតួអក្សរខ្មែរ ប៉ុន្តែពុំអាចធ្វើទៅបាន ដោយមានការប្រឆាំងយ៉ាងខ្លាំងក្លាពីព្រះសង្ឃខ្មែរ។ សូមយល់ស្រប តាមសេចក្តីប្រកាសរបស់ក្រសួងអប់រំដែលទុកវចនានុក្រមខ្មែរទាំងពីរភាគរបស់សម្តេចជួនណាតក្នុងការប្រើប្រាស់ពាក្យខ្មែរ និងទុកជាមូលដ្ឋានក្នុងការបង្កើតពាក្យថ្មីៗទៀត។ មួយទៀត ពាក្យខ្មែរខ្លះដែលបានកែប្រែនោះ ត្រូវតែត្រឡប់សរសេរដូចដើមវិញ គឺដូចសម័យមុនឆ្នាំ១៩៧០ សម័យសម្តេចសង្ឃរាជជួនណាតគង់នៅ។ ត្រូវសរសេរពាក្យ «ឬ»និង«ឮ»ពេញតួវិញ ពាក្យណាដែលត្រូវសរសេរអក្សរ«ឡ»ត្រូវ

សរសេរ«ឡ»វិញ ពាក្យណាដែលត្រូវសរសេរជាមួយអក្សរ«ណ» ត្រូវសរសេរជាមួយ«ណ»វិញជាដើម។ នេះនិយាយអំពីការពុំយល់ស្រួបឲ្យកែប្រែពាក្យខ្លះរបស់ពាក្យខ្មែរ ដែលធ្លាប់សរសេរមកហើយ។

រាជបណ្ឌិតសភាកម្ពុជាគប្បីពិនិត្យឲ្យម៉ត់ចត់ ពាក្យណាដែលធ្លាប់ប្រើមកហើយពុំគួរកែប្រែទេ ដូចពីដើមសរសេរ«ឬ» ពេញតួ មិនគួរប្រែមក«រឺ» ដូច្នេះវិញឡើយ។ ឯពាក្យបង្កើតថ្មីក៏គួរជ្រើសរើសមើលពាក្យខ្មែរសុទ្ធជាដំបូង បើគ្មានទេគួរខ្ចីពីបាលីនិងសំស្ក្រឹត ដើម្បីបង្រួប់ពាក្យប្រើ គួរជ្រើសរើសបុគ្គលិកធ្វើការខ្លះ ដែលចេះភាសាបាលីនិងសំស្ក្រឹតផង។ ពាក្យខ្មែរដែលចេញពីបាលីនិងសំស្ក្រឹត ត្រូវរក្សាទុកពាក្យដើម ដូចជាពាក្យសំស្ក្រឹតថា«ប្រយោជនំ» ខ្មែរថា«ប្រយោជន៍» ដោយសរសេរទណ្ឌឃាត«៍» បដិសេធលើ«ន»មិនឲ្យអាន។ ភាសាបារាំងនិងអង់គ្លេសមានពាក្យច្រើនណាស់ ដែលយកមកពីក្រិកនិងឡាតាំង ដូចពាក្យបារាំងថា Cholérat គេអានថា «កូឡេរ៉ា» គេមិនអានថា«សូឡេរ៉ា»ទេ អក្សរ«H»គេមិនអានទេ ប៉ុន្តែគេរក្សាទុក«H»នេះតាមពាក្យដើម។

សព្វថ្ងៃនេះ ការអានក៏មានការឃ្លៀងឃ្លាតពាក្យខ្លះ ដូចពាក្យថា«អត្តសញ្ញាណប័ណ្ណ»ត្រូវអាន «អត្តៈសញ៉្ញាណៈប័ណ្ណ» ព្រោះអក្សរ«ញ្ញា» ទៅជា«ញ៉្ញា» ដោយមានអក្សរ«ស» សម្លេងស្រាលនៅពីមុខ។ ដូចពាក្យថា«ទស្សនា»«សាសនា» ត្រូវមាន«ណា» មិនត្រូវអានថា«នា»ទេ។ ពាក្យថា«ក្រោមអធិបតីភាព» អ្នកខ្លះអានថា«ក្រោមអធិបតីយភាព» ពុំដឹងថា«យ»មកពីណាទេ។ ពាក្យ«ឯករាជ្យ» សរសេរមានជើង«យ»នៅពីក្រោម«ជ» គឺជានាមមាន«ភាព»នៅក្នុងនោះហើយ មិនត្រូវសរសេរឬនិយាយថា«ឯករាជ្យភាព»ទេ ទៅជា«ភាព»ពីរដង។ សព្វថ្ងៃនេះឮតែស្រីៗនិយាយ«ចាំ»នៅខាងចុងពាក្យ ដូចពាក្យថា អញ្ជើញអង្គុយចាំ ខ្ញុំសុខសប្បាយទេចាំ នេះជាវប្បធម៌ថៃចូលមកជ្រៀតជ្រែកវប្បធម៌ខ្មែរដោយពុំដឹងខ្លួន។

ៜៜៜៜៜ

# ៣- សិល្បៈអាចជាយានអប់រំសីលធម៌

មធ្យោបាយអប់រំមនុស្សឲ្យមានសីលធម៌មានវិធីជាច្រើនយ៉ាង ក្នុងវិធីនោះ វិស័យសិល្បៈក៏ជាយានមួយយ៉ាងសំខាន់ក្នុងការបង្កប់អត្ថន័យក្នុងការអប់រំ។ យ៉ាងណាមិញ សិល្បៈខ្មែរដូចជាចម្រៀងចាប៉ីចម្រៀងអាយ៉ៃកុនល្ខោនរហូតចម្រៀងសម័យទំនើបជាដើម អាចធ្វើជាយានសំរាប់ផ្សាយវប្បធម៌សាសនារហូតនយោបាយ។ នៅសម័យពុទ្ធកាល មានដំណាលថាពេលដែលព្រះពោធិសត្វព្រះឥសីសិទ្ធត្ថៈធ្វើទុក្ករកិរិយាយ៉ាងតឹងរ៉ឹងដើម្បីរកធម៌ត្រាស់ដឹង ពេលនោះ ព្រះឥន្ទមកដេញពិណច្រៀងជាប្រស្នាថា **ពិណកាលណារឹតខ្សែតឹងពេកអាចដាច់ខ្សែដេញពុំឮ រឹតធូរពេកក៏ដេញពុំឮ បើរឹតកុំឲ្យតឹងពេកកុំធូរពេកទើបដេញឮហើយពីរោះ។** សម្លេងនេះបានឮដល់ព្រះពោធិសត្វព្រះអង្គបានយកជាគតិ ហើយលះបង់ការព្យាយាមដ៏តឹងរ៉ឹងផ្លូវខុសនេះ ព្យាយាមផ្លូវកណ្ដាលវិញ ទើបត្រាស់ដឹង។ ប៉ុន្តែក្នុងសៀវភៅពន្លឺអាស៊ីទ្វីបវិញ ពុំនិយាយថាព្រះឥន្ទដេញពិណដូចក្នុងពុទ្ធប្រវត្តិទេ គឺនិយាយពីអ្នកភ្លេងធម្មតាដើរកាត់តាមផ្លូវដែលព្រះពោធិសត្វធ្វើទុក្ករកិរិយា ហើយនារីម្នាក់ជាសមាជិកក្រុមភ្លេងនោះ ច្រៀងទៅកាន់អ្នករឹតពិណមាន

ន័យដូចពោលមកហើយ។ ដូច្នេះបញ្ជាក់ថា **ព្រះពោធិសត្វ ព្រះសិទ្ធត្ថបានយកពាក្យរបស់អ្នកចម្រៀងមកពិចារណាបានរកឃើញផ្លូវត្រាស់ដឹង** ដែលកើតមានតាំងពីសម័យពុទ្ធកាល។

ដូចគ្នានេះដែរ នៅប្រទេសកម្ពុជា ប្រជាពលរដ្ឋខ្មែរបាននិយាយថា ស្មៀនឈិនចំរៀងអារ៉ៃយ៉េបានច្រៀងធម៌អាថ៌មានច្រៀងរឿងពុទ្ធប្រវត្តិជាដើមកាលពីមុន។ បច្ចុប្បន្ននេះទៀតប្រាជ្ញឈ្លួនអ្នកចំរៀងចាប៉ីច្រៀងរឿងពុទ្ធប្រវត្តិ ច្រៀងរឿងនគរកាយគតិលោក ប្រៀបគតិធម៌ ច្រៀងច្បាប់ក្រមង៉ុយ ច្បាប់កេរ្តិ៍កាលជាដើម។ ព្រះពុទ្ធបានហាមមិនឲ្យពុទ្ធបរិស័ទអ្នករក្សាសីល៨ស្តាប់ចំរៀងក្នុងយប់មួយថ្ងៃមួយនោះ ដោយសារចំរៀងទាំងនោះតែងច្រៀងទាក់ទងនឹងផ្លូវកាមគុណ រូបសម្លេងក្លិនរសសម្ផស្សដែលនាំឲ្យចិត្តសៅហ្មង ដែលពុំមែនជាចំរៀងអប់រំឲ្យចិត្តស្ងប់បរិសុទ្ធ។ ចំណែក ចម្រៀងបូរាណក្តី ចម្រៀងសម័យក្តីមានច្រើនប្រភេទ គឺចម្រៀងស្នេហាជាតិ ចម្រៀងប្រវត្តិសាស្រ្តចម្រៀងមនោសញ្ចេតនា ចម្រៀងបណ្តុះឲ្យមានគុណធម៌មានសីលគុណជាដើម។ ប៉ុន្តែចម្រៀងខ្មែរសព្វថ្ងៃនេះ ច្រើននិពន្ធនិងច្រៀងចំរៀងមនោសញ្ចេតនារវាងបុរសនិងស្រ្តី ពុំសូវមានតែង

និពន្ធឲ្យមនុស្សមានគុណសម្បត្តិឆ្ពោះទៅរកការគោរពសិទ្ធិគ្នា ការមានសីលធម៌ឡើយ។ មានកុនខ្មែរនិងចម្រៀងខ្មែរខ្លះ តែងនិពន្ធនិងច្រៀងមានលក្ខណៈប្រើអំពើហឹង្សា ការរំលោភសិទ្ធិគ្នា ការប្រើល្បិចបំផ្លាញគ្នា ស្នេហាក្បត់ចិត្តគ្នាជាដើម។ បើយុវជននិងយុវនារីខ្មែរមើលនិងស្តាប់អាចយកតម្រាប់តាម ព្រោះកុនល្ខោនចម្រៀងមានឥទ្ធិពលខ្លាំងណាស់ទៅលើយុវជនក្នុងបឋមវ័យដែលជាវ័យនៅទន់ខ្សោយខាងប្រាជ្ញាស្មារតី។ មានអ្នកស្នេហាសីលធម៌ម្នាក់និយាយថា មានចម្រៀងមួយបទរបស់ស៊ិនស៊ីសាមុតច្រៀងសម្លាប់ប្រពន្ធនៅពេលដែលប្រពន្ធមានចិត្តក្បត់។ គាត់មានប្រសាសន៍ថា ចម្រៀងបែបនេះមិនត្រូវយកមកច្រៀងទេ ព្រោះជាការបង្រៀនមនុស្សឲ្យក្បត់ចិត្តគ្នានិងឲ្យប្រើធម៌ហឹង្សា។ គាត់មានប្រសាសន៍ទៀតថា មានចម្រៀងមួយបទទៀតរបស់ស៊ិនស៊ីសាមុតដែលទាក់ទងនឹងពុទ្ធសាសនាថា «អាំអើយស្រីអាំ ព្រះពុទ្ធលោកផ្តាំឲ្យអាំគូនឹងបង» នេះពុំមែនជាពាក្យលើកតម្កើងព្រះពុទ្ធសាសនាទេ គឺជាពាក្យបង្អាប់ព្រះពុទ្ធសាសនា។ យោបល់គាត់នេះជាយោបល់ត្រូវ ព្រោះព្រះពុទ្ធជាបុគ្គលបរិសុទ្ធផុតចាកគ្រឿងកង្វល់ទាំងអស់ មិនត្រូវលើកយកព្រះពុទ្ធជាបុគ្គលបរិសុទ្ធមកលាយឡំជាមួយមនុស្ស

បុថុជ្ជនដែលប្រព្រឹត្តកាមគុណដូច្នេះឡើយ។ ក្រសួងវប្បធម៌ត្រូវតែហាមកុំឲ្យចេញផ្សាយនូវចំរៀងបែបនេះ ព្រោះជាពាក្យបន្ថោកតម្លៃព្រះពុទ្ធ ឲ្យចុះទាបឲ្យនៅស្មើនឹងមនុស្សធម្មតា ហើយជាការខុសការពិតផង ព្រោះពុំមែនព្រះពុទ្ធអង្គណាដែលផ្គុំបុរសស្រ្តីណាឲ្យជួបគ្នាឡើយ នេះគ្រាន់តែជាការប្រឌិតរបស់អ្នកនិពន្ធប៉ុណ្ណោះ។

មួយទៀត មានបទចម្រៀងខ្លះ កាលណាមានវិបត្តិស្នេហា គេពោលបន្ទោសថា មកអំពីព្រះព្រហ្មលិខិត ដែលមានន័យថាខ្លួនមានទុក្ខទោសព្រាត់ប្រាសគ្នានេះ មកអំពីព្រះព្រហ្មលោកចារ លោកសរសេរមកឲ្យខ្លួនរងគ្រោះដូច្នេះ។ នេះជាគំនិតសាសនាព្រាហ្មណ៍ បើតាមន័យរបស់ព្រះពុទ្ធសាសនាវិញត្រូវប្រើពាក្យថាកម្មលិខិតវិញ ដើម្បីឲ្យស្របតាមខ្មែរជាអ្នកព្រះពុទ្ធសាសនា ព្រោះវិបត្តិស្នេហានេះជួនកាលកើតពីខ្លួនឯងដើរផ្លូវខុសជឿគេខុស គឺកម្មក្នុងបច្ចុប្បន្ននេះតែម្តង។ ចម្រៀងខ្លះណែនាំមនុស្សឲ្យប្រព្រឹត្តខុស ដូចបទថា បើធ្វើប្រពន្ធចុងគេក៏សុខចិត្តដែរឲ្យតែបានប្តីធ្វើធំ ត្រង់នេះពុំមែនជាការពិតឡើយ។ ចម្រៀងរបៀបនេះ គួរតែក្រសួងវប្បធម៌និងក្រសួងពត៌មានបិទកុំឲ្យចេញផ្សាយ ព្រោះនាំឲ្យខូចតម្លៃវប្បធម៌ខ្មែរ។ បើនិយាយពី

អ្នកកំប្លែងខ្មែរវិញ ក៏និយាយអាសអាភាសខ្លាំងណាស់ គ្មានពាក្យថ្លៃថ្នូរឡើយ គឺនិយាយនៅតែក្នុងន័យភេទប្រុសភេទស្រីហ្នឹងឯង។ បើកំប្លែងគ្រាន់តែឲ្យគេសើចសប្បាយ ប៉ុន្តែគ្មានន័យសំរាប់ដាស់ស្មារតីមនុស្សឲ្យចេះគិតចេះពិចារណាដើម្បីរកភាពថ្លៃថ្នូរទេ តើការកំប្លែងនោះមានប្រយោជន៍អ្វីដល់សង្គមខ្មែរ? គួរតែក្រសួងវប្បធម៌អប់រំអ្នកកំប្លែងទាំងនោះឲ្យប្រើពាក្យថ្លៃថ្នូរនិងស្លៀកសំលៀកបំពាក់ឲ្យបានសមរម្យផង។ នៅប្រទេសជឿនលឿន ការកំប្លែងគេប្រើពាក្យថ្លៃថ្នូរណាស់ ហើយរឿងស្នេហាគេស្ទើរតែឈប់និយាយទៅហើយ ព្រោះគេយល់ថារឿងធម្មតាគេនិយាយកំប្លែងអ្វីផ្សេងពីនេះ ហើយសំលៀកបំពាក់គេស្លៀកពាក់សមរម្យធម្មតា។ អ្នកកំប្លែងខ្មែរគប្បីកែសម្រួលនូវការកំប្លែងរបស់ខ្លួនឲ្យមានតម្លៃទៅលើការអប់រំវិញ កុំប្រើទម្លាប់ចាស់ដដែលៗនៅតែជុំវិញភេទប្រុសនិងភេទស្រី។ មួយទៀតគេសង្កេតឃើញថា អ្នកចម្រៀងអាយ៉ៃក្មេងៗដូចជាច្រៀងមានសីលធម៌ជាងអ្នកចម្រៀងចាស់ៗ។ សុភាសិតបូរាណខ្មែរឬពាក្យព្រះពុទ្ធណាមួយមុននឹងយកមកច្រៀង គួរយកទៅពិគ្រោះជាមួយលោកអ្នកចេះដឹងឲ្យជួយបំភ្លឺបន្ថែម ដើម្បីកុំឲ្យអ្នកចម្រៀងយល់ច្រឡំ យកមកច្រៀងខុស។

មានតួអង្គភាពយន្ត(កុន)និងចម្រៀងខ្លះទៀតនិយាយនៅពេលដែលធ្វើបុណ្យកុសលណាមួយ ដូចជាដាក់បាត្រព្រះសង្ឃហែកឋិនជាដើមថា ធ្វើបុណ្យនេះដើម្បីទទួលផលជាតិក្រោយ។ ពាក្យនេះត្រូវបានមួយភាគ ប៉ុន្តែពុំត្រូវសព្វទេ ដោយបុណ្យកុសលដែលធ្វើបានផលតាំងពីជាតិនេះទៅ ព្រោះអ្នកធ្វើបុណ្យកុសលតែងមានចិត្តរីករាយជ្រះថ្លាមានគេស្រឡាញ់រាប់អានជាដើម ពុំមែនចាំតែជាតិក្រោយទេ។ ដូច្នេះ អ្នកដែលតែងកុនល្ខោននិងបទចំរៀងដែលទាក់ទងនឹងព្រះពុទ្ធសាសនាគួរទៅពិគ្រោះសាកសួរអ្នកចេះដឹងព្រះពុទ្ធសាសនា កុំឲ្យភ្លាំងភ្លាត់បែបនេះ។ គេអាចពោលថា ធ្វើបុណ្យដើម្បីសេចក្តីសុខ គឺសុខក្នុងជាតិនេះនិងជាតិខាងមុខ ដោយសំអាងពុទ្ធភាសិតថា ការនស្សំនូវបុណ្យនាំមកនូវសេចក្តីសុខក្នុងលោកទាំងពីរ គឺលោកនេះនិងលោកខាងមុខ។ ក្នុងអានិសង្សនៃការធ្វើបុណ្យមានការធ្វើទានជាដើមមានអានិសង្ស៥យ៉ាង។ ក្នុង៥យ៉ាងនោះ មាន៤យ៉ាងឲ្យផលក្នុងបច្ចុប្បន្ន មានតែ១ទេសំរាប់ឲ្យផលក្នុងលោកខាងមុខ បន្ទាប់ពីទទួលមរណភាពទៅ។ អានិសង្ស៤យ៉ាងនោះមានជាអាទិ៍ថា អ្នកធ្វើបុណ្យមានធ្វើទានជាដើមរមែងមានគេស្រឡាញ់គេរាប់អានច្រើន កេរ្តិ៍ឈ្មោះល្អផ្សាយទៅ លោកអ្នក

សប្បុរសតែងគប់រក ទៅទីណាមានសេចក្ដីក្លាហានមិនសំយុង មុខចុះ ដោយខ្លួនមានគុណធម៌ មិនមានកំហុស។ ឯអានិសង្ស សំរាប់លោកខាងមុខមានតែមួយ គឺបន្ទាប់ពីចែកស្ថានទៅ នឹង ទៅសោយសុខក្នុងសុគតិភព គឺបានកើតជាមនុស្សឬទេវតា។

ចំពោះចម្រៀងចាប៉ី គេសរសើរលោកតាប្រាជ្ញឈួន ព្រោះ គាត់ច្រៀងចាប់ចុងជួនល្អ ប្រើពាក្យថ្លៃថ្នូរ សម្លេងធ្ងន់ពីរោះ គាត់ច្រៀងចម្រៀងជាច្រើនទាក់ទងនឹងព្រះពុទ្ធសាសនានិង ច្បាប់បូរាណទូន្មានកូនចៅផ្សេងៗ។ គួរយកលោកតាប្រាជ្ញ ឈួនធ្វើជាគ្រូបង្ហាត់ក្នុងសាកលវិទ្យាល័យវិចិត្រសិល្បៈចំពោះ វិជ្ជាចម្រៀងចាប៉ីនេះ ដល់និស្សិតជាការល្អណាស់។ ចំណែកគ្រូ ចម្រៀងចាប៉ីដទៃទៀត អ្នកស្ដាប់និយាយថា ពុំសូវពីរោះ ច្រៀង ច្រើនស្រែក ប្រើពាក្យពុំថ្លៃថ្នូរ កំប្លែងខុសការពិត ដូចកូនសិស្ស លោកតាពូចៅដែជាដើម។ ចំរៀងចាប៉ីគួរយកតាមដំណើរ លោកតាប្រាជ្ញឈួន ព្រោះដំណើរច្រៀងមានលើកដាក់ មាន សម្លេងថ្នម ហើយប្រើពាក្យល្អទាន់សម័យ ទាន់ការលូតលាស់ ខាងអក្សរសាស្ត្រ ដែលអាចឲ្យយុវជនសម័យថ្មីស្ដាប់បាន ហើយគាត់ច្រើនច្រៀងចំពោះប្រធាបទដែលទាក់ទងទៅនឹងការ អប់រំផង។

តួនាទីចម្រៀងក៏អាចជាយានសំរាប់អប់រំមនុស្សឆ្ពោះទៅរកសេចក្តីសុខចំរើនភាពថ្លៃថ្នូររុងរឿង ព្រោះមានចម្រៀងស្នេហាជាតិ ស្នេហារវាងមាតាបិតានិងបុត្រ ស្នេហាសីលធម៌ ស្នេហាសាសនាជាដើម។

ចម្រៀងខ្មែរភាគច្រើន ឮតែអូនបងៗ ដោយពុំសូវមានបទចម្រៀងមានន័យឲ្យខ្មែរចេះស្រឡាញ់រាប់អានគ្នា គោរពច្បាប់ទម្លាប់របស់ប្រទេស ថែរក្សាទឹកដីព្រៃព្រឹក្សា ឲ្យខ្លាចបាបគោរពចាស់ព្រឹទ្ធាចារ្យមាតាបិតាជាដើម។ ក្នុងន័យនេះ ពុំមែនបានសេចក្តីថា ឲ្យអ្នកនិពន្ធតែងតែរឿងស្នេហាជាតិដូចចម្រៀងពួកខ្មែរក្រហមនោះឡើយ។ ប៉ុន្តែការតែងចម្រៀងគ្រាន់តែឲ្យមនុស្សអណ្តែតអណ្តូងវង្វេងក្នុងកាមគុណ ឬឲ្យមនុស្សច្រណែនឈ្នានិសគ្នា ពុំគិតអំពីអំពើគ្រប់យ៉ាង ដែលត្រូវតែធ្វើឲ្យមានភាពថ្លៃថ្នូរទេ ចម្រៀងបែបនេះ ជាពិសពុលរបស់សង្គម។ ក្នុងបទចម្រៀង គេអាចបញ្ចូលស្នេហាខ្លះដើម្បីឲ្យស្របតាមចំណង់ចំណូលចិត្តរបស់មនុស្សបុថុជ្ជនដែលពុំមែនជាព្រះអរហន្ត ប៉ុន្តែគេបញ្ចូលក្នុងភាពថ្លៃថ្នូរតាមប្រពៃណីជាតិ គេពុំបញ្ចូលរឿងស្នេហានេះរហូតធ្វើឲ្យមនុស្សងប់ក្នុងកាមគុណ រហូតភ្លេចកិច្ចការគ្រួសារនិងកិច្ចការសង្គមឡើយ។ ឧទាហរណ៍ គេលាបស្ករ

នៅជុំវិញថ្នាំល្វីងមួយគ្រាប់ ដើម្បីបញ្ឆោតឲ្យក្មេងលេប ក្នុងគោលបំណងដើម្បីឲ្យជារោគដោយសារថ្នាំនោះមានជាតិល្វីង ឯស្ករគ្រាន់តែជាមធ្យោបាយឲ្យក្មេងសុខចិត្តលេបប៉ុណ្ណោះ ពុំមែនដាក់ស្ករច្រើនពេក រហូតដល់ក្មេងឈឺពោះនោះឡើយ។ យ៉ាងណាមិញ ស្ករប្រៀបដូចជាគេបញ្ចូលស្នេហានៅក្នុងបទចម្រៀង ឯថ្នាំគឺគេបង្កប់ន័យទូន្មាននៅក្នុងបទនោះ ឲ្យមនុស្សប្រព្រឹត្តល្អបែបណាមួយ។ ដូច្នេះ អ្នកតែងបទចម្រៀងគួរតែអប់រំឲ្យមានចំណេះបន្ថែម ដើម្បីឲ្យកម្រិតវិជ្ជាជីវៈនេះ កាន់តែល្អប្រសើរឡើង។

រឿងអក្សរសិល្ប៍បោះពុម្ពជាសៀវភៅ យកមកលេងជាល្ខោនក្ដី ជាភាពយន្តក្ដី ជាយានមួយដ៏សំខាន់មួយទៀត ក្នុងការដឹកនាំអ្នកទស្សនាអានឲ្យចាប់អារម្មណ៍ក្នុងស្នាដៃរបស់ខ្លួន ប្រសិនបើអ្នកនិពន្ធប្រសប់ប្រើសិល្បវិធីស្របតាមប្រយោជន៍របស់សង្គម។ អ្នកសិក្សាបានជ្រាបហើយថា ចលនាអក្សរសិល្ប៍មានបួនផ្នែក គឺចលនាអក្សរសិល្ប៍ពុទ្ធនិយម ចលនាអក្សរសិល្ប៍ព្រហ្មញ្ញនិយម ចលនាអក្សរសិល្ប៍ខេមរនិយម និងចលនាអក្សរសិល្ប៍បរទេសនិយម។ ចំពោះអក្សរសិល្ប៍ខ្មែរ ទោះបីអ្នកនិពន្ធតែងរឿងអក្សរសិល្ប៍បែបខេមរនិយមក៏ដោយ

ក៏នៅតែមានទំនាក់ទំនងនឹងពុទ្ធសាសនាដែរ ព្រោះទំនៀមទម្លាប់ខ្មែរស្ទើរតែគ្រប់ផ្នែកទាក់ទងនឹងពុទ្ធសាសនា។ បច្ចុប្បន្ននេះ ពេលចាប់ដងប៉ាក្កាឡើងសរសេរ អ្នកនិពន្ធគប្បីសម្លឹងមើលនូវសេចក្តីត្រូវការរបស់សង្គមខ្មែរសព្វថ្ងៃនេះ គឺត្រូវការចំណេះចេះដឹង ត្រូវការអភិវឌ្ឍន៍សីលធម៌ឲ្យខ្ពស់ឡើងវិញ ត្រូវការសន្តិភាព ត្រូវការចំរើនលូតលាស់ខាងសង្គមកិច្ច។ អក្សរសិល្ប៍បំរើសង្គម គឺអក្សរសិល្ប៍មានអត្ថន័យបង្ហាញចំណេះចេះដឹង បង្ហាញអំពីទោសនិងគុណ បង្ហាញអំពីការចំរើននិងវិនាសដែលជាលទ្ធផលកើតចេញមកអំពីអំពើល្អនិងអាក្រក់ក្នុងផ្ទៃរឿងដល់អ្នកទស្សនាអាន។ អ្នកនិពន្ធខ្លះចូលចិត្តតែងរឿងប្រពន្ធចុងប្រពន្ធដើមច្រណែនឈ្នានិសបៀតបៀនគ្នា ពុំសូវមានតែងប្តីប្រពន្ធមានចិត្តស្មោះត្រង់នឹងគ្នាមួយនឹងមួយ ស្របតាមប្រពៃណីខ្មែរឡើយ។ ជួនកាលអ្នកនិពន្ធខ្លះតែងតាមមនោសញ្ចេតនាផ្ទាល់ខ្លួន ខ្លះតែងរេឬទំនោរទៅរកវប្បធម៌បរទេស ដោយពុំបានគិតអំពីមនោគមវិជ្ជាជាតិរបស់ខ្លួនឡើយ។

សម័យសកលភាវូបនីយកម្មនេះ ខ្មែរក៏ត្រូវប្រុងប្រយ័ត្នរបស់ណាដែលខ្មែរគួរទទួលយកនិងមិនគួរទទួលយក។ វិជ្ជាបច្ចេកទេសគ្រប់ផ្នែកដូចជាវិជ្ជាពេទ្យជាដើម គួរទទួលយក

ដោយសិក្សានៅក្នុងប្រទេសនិងបញ្ជូននិស្សិតទៅសិក្សានៅក្រៅប្រទេស។ ចំពោះវប្បធម៌បរទេសដែលមិនស្របតាមប្រពៃណីដ៏ឧត្តុងឧត្តមរបស់ខ្មែរ មិនគួរទទួលយកទេ ដូចជាថ្ងៃបុណ្យនៃសេចក្ដីស្រឡាញ់ដែលយុវជននិងយុវនារីខ្មែរយកមកក្រឡៃថាបុណ្យសង្សារ (St. Valentine day) ព្រោះធ្វើឲ្យខូចទំនៀមទម្លាប់ខ្មែរ។ ត្រូវបិទទស្សនាវដ្ដី សៀវភៅនិងវីដេអូអាសអាភាស កុំឲ្យចូលមកប្រទេសកម្ពុជា ក៏ដូចជាទូរទស្សន៍ខ្សែកាបណាដែលមានរឿងអាសអាភាស ក៏គួរពិចារណាបិទដែរ ព្រោះយុវវ័យមើលនាំឲ្យខូចសតិស្មារតីរវើរវាយក្នុងផ្លូវកាមគុណ ខូចការសិក្សាខូចតម្លៃយុវជនដែលជាធនធានមនុស្សរបស់ប្រទេស។ តាមធម្មតាការបើកឲ្យមានសកលភាវូបនីយកម្ម អាចលូតលាស់ទាំងល្អទាំងអាក្រក់ ត្រូវធ្វើច្បាប់បិទការលូតលាស់ផ្នែកខាងអាក្រក់។ ប្រៀបដូចភ្លៀងធ្លាក់លើផែនដី ធ្វើឲ្យស្មៅក៏ដុះលូតលាស់ល្អ សន្ទូងរបស់អ្នកស្រែក៏ផ្ដើមលូតលាស់ដែរ ប៉ុន្តែបើស្មៅដុះរុំព័ទ្ធសន្ទូង ធ្វើឲ្យសន្ទូងក្រិនមិនសូវលូតលាស់ល្អ គេត្រូវកាត់ស្មៅចោលដើម្បីឲ្យសន្ទូងលូតលាស់ល្អ។ យ៉ាងណាមិញ ត្រូវបិទវប្បធម៌បរទេសដែលមិនមានតម្លៃសំរាប់ខ្មែរ ហើយរក្សាការពារវប្បធម៌ដ៏មានតម្លៃរបស់ខ្មែរ ជាអត្តសញ្ញាណ

ជាតិ។ ស្មៅប្រៀបដូចជាវប្បធម៌មិនល្អសំរាប់ខ្មែររបស់បរទេស សន្ទូងប្រៀបដូចជាវប្បធម៌ដ៏ល្អរបស់ខ្មែរជាបេត្តិកភណ្ឌជាតិ ត្រូវថែរក្សាឲ្យគង់វង់។

ឈឈឈឈឈ

# ៤- កេរ្តិ៍ដំណែលបុព្វបុរសខ្មែរ

បុព្វបុរសខ្មែរបានបន្សល់ទុកនូវកេរ្តិ៍ដំណែលជាច្រើនឲ្យកុលបុត្រកុលធីតាខ្មែរ ប៉ុន្តែកេរ្តិ៍ដំណែលខ្លះបានបាត់បង់ដោយសារកង្វះការថែររក្សាដោយការប្រុងប្រយ័ត្ន។ កេរ្តិ៍ដំណែលទាំងនោះមានជាអាទិ៍ គឺទឹកដី។ ដូនតាខ្មែរបានកាន់កាប់ទឹកដីមួយកន្លែងគឺ**ប្រទេសកម្ពុជា** ជាទឹកដីមានជីវជាតិ មានធាតុអាកាសល្មមមិនក្ដៅពេកមិនត្រជាក់ពេក។ ជាទីកន្លែងដ៏ល្អ ពុំដែលមានគ្រោះធម្មជាតិ ដូចជារញ្ជួយផែនដី ភ្លើងភ្នំផ្ទុះជាដើម។ សម័យមហានគរចាប់ពីសតវត្សរ៍ទី៩ដល់ទី១៣ ប្រទេសកម្ពុជាជាមហាអំណាចនៅអាស៊ីភាគអគ្នេយ៍ មានទឹកដីធំទូលំទូលាយមានអរិយធម៌ដ៏រុងរឿង ហើយបានជះឥទ្ធិពលរបស់ខ្លួនទៅលើប្រទេសជិតខាងទៀតផង។ បច្ចុប្បន្ននេះ ទឹកដីដែលបុព្វបុរសខ្មែរបានប្រគល់ឲ្យកូនចៅខ្មែរបានរួមតូច ហើយកំពុងតែបាត់បង់តទៅទៀតដោយប្រទេសជិតខាងរំលោភយក ដោយសារតែខ្មែរខ្លួនឯងបែកបាក់សាមគ្គីគ្នា។ កេរ្តិ៍ដំណែលធម្មជាតិមួយទៀត គឺព្រៃឈើដែលគ្របដណ្ដប់ពាសពេញប្រទេសកម្ពុជាចំនួនជាង៧០ភាគរយបានត្រូវកាប់បំផ្លាញ។ ការពុំបានថែរក្សា

កេរ្តិ៍ដំណែលនេះឲ្យនៅគង់វង់ដូចដើម បណ្តាលឲ្យមានទឹកជំនន់និងភ្លៀងពុំធ្លាក់តាមប្រក្រតី។

ដូនតាខ្មែរបានជ្រើសរើសឲ្យខ្មែរគោរពព្រះពុទ្ធសាសនាថេរវាទ ទុកជាមាគ៌ាសំរាប់ជីវិតប្រចាំថ្ងៃ ព្រោះព្រះពុទ្ធសាសនាថេរវាទជាមាគ៌ាមានសច្ចភាព ដែលបានចង្អុលបង្ហាញផ្លូវទៅកាន់សេចក្តីសុខចំរើនក្នុងសង្គមនិងផ្លូវទៅកាន់ការរំលត់ទុក្ខ។ ក្រៅពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ចាស់បូរាណខ្មែរបានតែងនិពន្ធជាច្បាប់ទូន្មានផ្សេងៗ សំរាប់ឲ្យកូនចៅខ្មែរប្រតិបត្តិតាម ដូចជាច្បាប់ប្រុស ច្បាប់ស្រី ច្បាប់ក្រម ច្បាប់កេរ្តិ៍កាលជាដើម ដែលច្បាប់ទាំងនោះច្រើនផ្អែកទៅលើមូលដ្ឋានព្រះពុទ្ធសាសនា។ សម្បត្តិសិល្បៈវប្បធម៌របស់ខ្មែរដ៏មានតម្លៃជាច្រើនទៀត ដែលខ្មែរលើកយកមកសិក្សានិងអនុវត្តសព្វថ្ងៃនេះ ដូចជាអក្សរសិល្ប៍ សិល្បៈរបាំ ចម្រៀងដូរ្យដន្ត្រី ល្ខោន ភាពយន្ត គំនូរ ចម្លាក់ សំណង់ ការសូនរូបជាដើម។ ប្រពៃណីទំនៀមទម្លាប់ផ្សេងៗ ដូចជាប្រពៃណីបុណ្យទាន ប្រពៃណីពេលកូនកើត ប្រពៃណីពេលរៀបអាពាហ៍ពិពាហ៍ ប្រពៃណីពេលស្លាប់ និងរបៀបគួរសមនឹងគ្នាពេលជួបគ្នាជាដើម។ កេរ្តិ៍ដំណែលដែលមានលក្ខណៈពិសេសមួយទៀត គឺ**ភាសា**និង**អក្សរ**។ ខ្មែរមាន

ឯកភាពខាងភាសានិយាយ គឺខ្មែរគ្រប់ខេត្តទាំងអស់ទូទាំងប្រទេសនិយាយស្តាប់គ្នាបានដោយប្រើភាសាតែមួយ គឺ **ភាសាខ្មែរ**។ បុព្វបុរសខ្មែរបានរៀបចំរចនាអក្សរសំរាប់សរសេរដែលមានរាងរៅនិងន័យរបស់ពាក្យព្រមទាំងសម្លេង ស្របទៅតាមភាសានិយាយជាលក្ខណៈពិសេសរបស់ខ្លួន។

វប្បធម៌ខ្មែរ មានតម្លៃដ៏ខ្ពង់ខ្ពស់ ដែលជាវប្បធម៌មានមូលដ្ឋានពីព្រះពុទ្ធសាសនា ដែលបង្រៀនមនុស្សឲ្យលះបង់អំពើអាក្រក់គ្រប់យ៉ាង សាងសេចក្តីល្អ ដុះខាត់ជំរះចិត្តឲ្យស្អាតបរិសុទ្ធ ព្រោះចិត្តអាក្រក់នាំឲ្យសាងអាក្រក់។ ដោយសារវប្បធម៌ល្អ ការយកមកអប់រំកូនចៅក៏បានល្អ។ ទំនៀមទម្លាប់ខ្មែរ ការអប់រំកូនចៅតែងស្ថិតនៅលើមនុស្សបីក្រុម គឺ**ឪពុកម្តាយ គ្រូបង្រៀន** និង**ព្រះសង្ឃព្រះពុទ្ធសាសនា**។ ឪពុកម្តាយខ្មែរជាពុទ្ធសាសនិកជន ដូច្នេះ ការអប់រំកូនចៅក៏យកគោលគំនិតរបស់ព្រះពុទ្ធសាសនាមកពន្យល់ឲ្យកូនចៅអនុវត្តតាម។ ដូចជាឲ្យគោរពចាស់ព្រឹទ្ធាចារ្យ គោរពអ្នកមានសីល ឲ្យស្រឡាញ់រាប់អានបងប្អូន ឲ្យគោរពសិទ្ធិអ្នកដទៃ ហាមកូនចៅមិនឲ្យធ្វើនូវអំពើបាបជាដើម។ ព្រះពុទ្ធសាសនាបានពោលថា មនុស្សក្នុងសង្គម ដែលមានអ្នកធំអ្នកតូច អ្នកមានអ្នកក្រ គ្រូនិងសិស្ស

ឪពុកម្ដាយនិងកូន ស្វាមីនិងភរិយាជាដើម ត្រូវមានធម៌រៀងៗខ្លួន។ ធម៌ក្នុងទីនេះសំដៅយកការគោរពសិទ្ធិគ្នាទៅវិញទៅមកតាមមុខងាររបស់ខ្លួនដោយមិនបៀតបៀនគ្នា ទើបសង្គមគ្រួសារនិងសង្គមជាតិបានសុខចំរើន។ ជំនាន់ដើម កូនចៅប្រុសជំទង់ខ្មែរភាគច្រើនត្រូវម្ដាយឪពុកឲ្យទៅនៅវត្ត ដើម្បីបានសិក្សារៀនសូត្រអក្សរសាស្ត្រជាតិនិងសុំព្រះសង្ឃឲ្យជួយអប់រំកូនរបស់ខ្លួនឲ្យមានចរិយាល្អ រហូតឲ្យបួសជាសាមណេរជាភិក្ខុទៀតផង អនុវត្តមកដល់សព្វថ្ងៃនេះ។ ចំណែក កូនស្រីទោះបីមិនបានរស់នៅក្នុងវត្តមិនបានបួសដូចជាកូនប្រុស ប៉ុន្តែបានអប់រំចរិយាធម៌ពីឪពុកម្ដាយនិងពីសាលារៀនដែរ។ ដោយសារបានទទួលការអប់រំល្អនេះហើយ បានជាកូនចៅខ្មែរជំនាន់ដើមមិនដែលខូចកាចនឹងគ្នា គឺមិនដែលប្រព្រឹត្តកន្លងប្រពៃណីក្នុងផ្លូវកាមគុណអំពីភេទប្រុសភេទស្រីឡើយ។

ដោយសារឥទ្ធិពលព្រះពុទ្ធសាសនា បានធ្វើឲ្យជនជាតិខ្មែរស្រឡាញ់រាប់អានស្មោះត្រង់នឹងគ្នា ជឿបុណ្យជឿបាប ស្គាល់គុណស្គាល់ទោស បានដិតជាប់ក្នុងចិត្តជាអត្តសញ្ញាណរបស់ខ្លួន។ជនជាតិខ្មែរតែងជួយទុក្ខធុរៈគ្នាទៅវិញទៅមក ដូចជួយគ្នាក្នុងពេលសង់ផ្ទះ រៀបអាពាហ៍ពិពាហ៍កូនចៅ ពេលមានមនុស្ស

ស្លាប់ ពេលច្រូតស្រូវជាដើម។ ពេលខ្លះ បើមានការទាស់ទែងខ្វែងគំនិតគ្នា ជនជាតិខ្មែរនាំគ្នាទៅវត្តឲ្យព្រះសង្ឃជួយកាត់សេចក្តី។ ព្រះសង្ឃក៏ជួយសម្រុះសម្រួលតាមធម៌អាថ៌ សាមីខ្លួនក៏ជានានឹងគ្នាវិញទៅ។ ដូចបានពោលមកហើយ កេរ្តិ៍ដំណែលទាំងនេះ ដែលបុព្វបុរសខ្មែរបានបន្សល់ទុក ត្រូវជនជាតិខ្មែរគ្រប់គ្នារក្សាការពារឲ្យបានគង់វង់។

ឈឈឈឈឈ

# ៥- សាមគ្គីធម៌

ពាក្យថា **សាមគ្គី** ជាភាសាបាលី ខ្មែរក៏ប្រើពាក្យសាមគ្គីនេះដែរ ប្រែថា ការព្រមព្រៀងគ្នា ដំណើរស្រុះស្រួលគ្នា។ ឯពាក្យថា **សាមគ្គីធម៌** ប្រែថា ធម៌ព្រមព្រៀង វិធីឬរបៀបបែបបទនៃការព្រមព្រៀងគ្នា។ ចំណែក ពាក្យថា **សាមគ្គីភាព** ប្រែថា ភាពនៃសាមគ្គី ចរិយាឬសណ្តាប់ធ្នាប់នៃសាមគ្គី។ សាមគ្គីនេះ ជាធម៌របស់សប្បុរស ហើយទុកជាគុណសម្បត្តិចាំបាច់របស់មនុស្សម្នាក់ៗក្នុងសង្គម។ ពុទ្ធភាសិតមួយបទពោលថា **សាមគ្គី សមគ្គានំ តបោ សុខោ** ប្រែថា ការព្រមព្រៀងគ្នារបស់អ្នកព្រមព្រៀងគ្នាទាំងឡាយ ជា**តបធម៌**នាំឲ្យបានសេចក្តីសុខ។ មនុស្សរស់នៅក្នុងសង្គម ក្រៅពីកិច្ចការដែលត្រូវបំពេញប្រយោជន៍ខ្លួននិងគ្រួសារខ្លួន មានភារកិច្ចចាំបាច់មួយទៀតដែលត្រូវបំពេញដើម្បីជាតិ គឺការការពារជាតិនិងកសាងជាតិ ត្រូវការកម្លាំងនិងឋាមពលគ្រប់ផ្នែកនិងគ្រប់គ្នាដើម្បីជាតិ នៅក្រោមច្បាប់ទម្លាប់នៃស្រុកទេសរបស់ខ្លួន។ មិនត្រឹមតែជាតិរបស់ខ្លួនទេ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ មនុស្សត្រូវមានចិត្តមេត្តាករុណាឲ្យទូលាយជួយដោះស្រាយបញ្ហាសាកលលោក

ផង ដែលក្នុងបាលីថា **អប្បមញ្ញាព្រហ្មវិហារ** ដើម្បីឲ្យពិភព លោកបានសុខសន្តិភាព ព្រោះថា នៅលើផែនដីដែលមនុស្ស រស់នៅនេះ បើមានកន្លែងណាមួយមានអសន្តិសុខ អាចមាន ផលវិបាកអាក្រក់ដល់កន្លែងដទៃទៀត។ ដូច្នេះហើយបានជា ព្រះសម្ពុទ្ធជាមួយនឹងសេចក្តីករុណារបស់ព្រះអង្គ បានបបួល មនុស្សក្នុងលោកឲ្យព្រួតដៃគ្នាសាងសន្តិភាពសាកលលោក។ ដើម្បីសន្តិភាពពិភពលោក ត្រូវមានសន្តិភាពផ្លូវចិត្តនៃមនុស្ស ម្នាក់ៗ ព្រោះមនុស្សម្នាក់ៗជាសមាជិករបស់សង្គម។ ដូចជា ពលរដ្ឋខ្មែរគ្រប់ឋានៈត្រូវធ្វើការតាមមុខងាររៀងខ្លួនដើម្បីរក្សា ការពារទឹកដី ការពារឯករាជ្យ ការពារអធិបតេយ្យរបស់ជាតិខ្លួន កុំលក់ខ្លួនឲ្យបរទេសសម្លាប់ជាតិឯង។

ពាក្យថា សាមគ្គីនាំឲ្យបានសុខនេះ គឺសាមគ្គីបំពេញអំពើ ល្អ អំពើជាកុសល បើសាមគ្គីបំពេញអំពើជាអកុសលវិញមិន ស្របតាមពុទ្ធភាសិតនេះ ដែលថាសាមគ្គីនាំឲ្យបានសុខឡើយ តែជាសាមគ្គីនាំឲ្យមានទុក្ខទៅវិញ ក្នុងន័យថា រួមគ្នាបំពេញអំពើ បាបនឹងទទួលផលបាបរួមគ្នា។ នៅក្នុង**សារាណីយធម៌**ដែល ប្រែថា ធម៌ជាទីតាំងនៃការរលឹកដល់មាន៦យ៉ាងនោះ មានធម៌ ២ប្រការយ៉ាងសំខាន់ដែលជាមូលដ្ឋានទ្រទ្រង់នូវសាមគ្គីធម៌

ឬជាធម៌នាំឲ្យកើតសាមគ្គី គឺ**ទិដ្ឋិឬទស្សនៈ** ការយល់ត្រូវគ្នាឬដូចគ្នា១ និង**សីលៈ** ការប្រព្រឹត្តត្រូវគ្នាឬដូចគ្នា១។ បើមនុស្សមានការយល់ត្រូវគ្នា ហើយការប្រព្រឹត្តល្អដូចគ្នាទៀត នឹងរត់រកគ្នាពុំខានឡើយ។ បើការយល់ផ្សេងគ្នា ការប្រព្រឹត្តក៏ផ្សេងគ្នាទៀត បើទោះបីកំពុងរួមគ្នាក៏ដោយ ថ្ងៃណាមួយគង់បែកគ្នាពុំខាន។ ក្រៅពីនោះ ធម៌ឲ្យកើតសាមគ្គី គឺការបានទទួលផលដូចគ្នា ប្រៀបដូចប្រទេសកម្ពុជាបានសុខសន្តិភាព ពលរដ្ឋខ្មែរគ្រប់ឋានៈក៏បានទទួលសុខសន្តិភាពដូចគ្នា។ ពាក្យថា **សាមគ្គី** ដែលរួមគ្នាបំពេញសេចក្តីល្អនោះ កុំច្រឡំការរួមគ្នា ដូចកុម្មុយនិស្តខ្មែរក្រហមរួមគ្នាបំពេញការងារជាសមូហភាព ផ្តាច់កម្មសិទ្ធិឯកជន រហូតបរិភោគអាហាររួមគ្នានោះឡើយ គឺរស់ទៅតាមលក្ខណៈឯកជន ប៉ុន្តែម្នាក់ៗត្រូវបំពេញកិច្ចដើម្បីជាតិខ្លួនស្របតាមច្បាប់របស់ប្រទេស។

ពាក្យខ្មែរនិយាយថា ចង្កើះតែមួយគេកាច់បាក់ ចង្កើះមួយបាច់គេកាច់ពុំបាក់ឡើយ។ ពាក្យមួយទៀតថា ខ្សែនៅរាយគ្នាគេទាញដាច់ តែបើវេញជាផ្លុងតែមួយ គេទាញពុំដាច់ឡើយ។ ក្នុងស្រីហិតោបទេសក៏មាននិយាយថា ការវេញចងបាច់វត្ថុអ្វីមួយសូម្បីតូចឆ្មារឲ្យរួមគ្នារមែងជាប់រឹងមាំបាន។ ដូចគេប្រមូល

ស្មៅវេញជាទន្លីងយកទៅធ្លឹងដំរីចុះប្រេងឲ្យជាប់បោលទៅណាពុំរួច។ មួយទៀត ពោលថា ព្រានបក្សីឃើញហ្វូងបក្សីស្រុះគ្នាទទះស្លាបហើររបើកលប់រត់រួចចេញពីលប់របស់ខ្លួនអស់ ក៏នឹកស្តាយណាស់ រត់បណ្តើរគិតបណ្តើរថា ហ្វូងបក្សីនេះ ស្រុះចិត្តចងគ្នាជាបាច់ស្មុះហើររបើកលប់រត់រួចទៅអស់រលីង តែបើវាចុះដីនៅវាយគ្នាដរាបណា វានឹងនៅក្នុងកណ្តាប់ដៃនៃអាត្មាអញដរាបនោះពុំខានឡើយ។ ដូច្នេះ សាមគ្គីជាកម្លាំងមួយដ៏ខ្លាំងក្លាអាចញុាំងប្រយោជន៍មួយឲ្យសម្រេចបាន ទោះបីការងារមានទំហំធំនិងពិបាកយ៉ាងណាក៏ដោយ។ ព្រះអរិយសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយប្រពៃដើម្បីកំចាត់បង់នូវកិលេសតណ្ហាអស់ហើយ ព្រះអរិយសង្ឃទាំងនោះ ទោះលោកគង់នៅឆ្ងាយពីគ្នា ក៏ទុកដូចជានៅជិតគ្នាដែរ ព្រោះលោកមានសម្មាទិដ្ឋិការយល់ត្រូវគ្នា មានការប្រតិបត្តិតាមសីលសមាធិបញ្ញាដូចគ្នា គឺលោកមានសាមគ្គីធម៌ដោយព្រះទ័យនិងព្រះទ័យជាប់ជានិច្ច។

ចំណែកសាមគ្គីភេទ គឺការបែកបាក់សាមគ្គីវិញ នឹងមានសេចក្តីអន្តរាយដល់សង្គមមនុស្សធ្ងន់ណាស់ ដូចជាសង្គ្រាមលោកទាំងពីរលើក កើតពីការបែកសាមគ្គីចែកជាបក្សពួកច្បាំង

យកជ័យជំនះរៀងខ្លួន។ ដូចជាប្រទេសកម្ពុជាច្បាំងកាប់សម្លាប់គ្នា ក៏កើតអំពីការបែកសាមគ្គីគ្នា មិនដោះស្រាយបញ្ហាប្រទេសខ្លួនដោយសន្តិវិធីតាមរបបប្រជាធិបតេយ្យ។ មានរឿងបូរាណមួយនិយាយថា ហង្សមួយមានក្បាលពីរ ដោយទទួលការញុះញុងពីខាងក្រៅ មិនបានសាកសួរគ្នាឲ្យដឹងរឿងពិតជាមុន ក៏បង្កើតជាជម្លោះនឹងគ្នា កើតអំពើហឹង្សាខាំគ្នារហូតដល់ស្លាប់ទៅ។

ដូចបានអធិប្បាយមកហើយ សាមគ្គីធម៌ដែលប្រែថា ធម៌ព្រមព្រៀងគ្នាជាគោលធម៌សំខាន់ណាស់ សំរាប់សេចក្តីសុខចំរើនក្នុងសង្គមតូចសង្គមធំរហូតសហគមន៍ពិភពលោក។ ក្នុងន័យនេះ បើនិយាយមកប្រទេសកម្ពុជា បើប្រទេសនេះរួបរួមគ្នានៅក្រោមច្បាប់របស់ប្រទេសនិងច្បាប់អង្គការសហប្រជាជាតិ ប្រទេសនេះនឹងមានស្ថេរភាពខាងនយោបាយ ហើយនឹងធ្វើឲ្យវប្បធម៌និងសេដ្ឋកិច្ចលូតលាស់ចំរើន។ ពង្រឹងជំហរផ្ទៃក្នុងឲ្យមានឯកភាពជាតិ ដំណោះស្រាយគ្រប់យ៉ាងក្នុងបញ្ហាជាតិត្រូវស្ថិតនៅក្នុងគ្របខណ្ឌច្បាប់ មិនប្រើហឹង្សាមានការសម្លាប់គ្នាជាដើម។ នេះជាកត្តាសំខាន់ អាចការពារឯករាជ្យអធិបតេយ្យជាតិនិងបូរណភាពទឹកដីរបស់ខ្លួនបាន ហើយបរទេសក៏មិនអាចលូកដៃចូលមកជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្មែរបានឡើយ។

# ៦- សុជីវធម៌ និងសីលធម៌

## ១. សុជីវធម៌

ពាក្យថា **សុជីវធម៌** ប្រែថា ធម៌ឬរបៀបរស់នៅសមរម្យ។ បានសេចក្តីថា ការរស់នៅដឹងលក្ខណៈនៃសង្គម ហើយអនុវត្ត តាមរបៀបបែបបទនៃសង្គមនោះ។ សុជីវធម៌នៃជនជាតិនីមួយៗ មានលក្ខណៈប្លែកៗគ្នា ស្របតាមវប្បធម៌ទំនៀមទម្លាប់នៃជាតិ របស់ខ្លួន។ ប៉ុន្តែ មានគោលមួយដូចគ្នា គឺការគួរសមនឹងគ្នាទៅ វិញទៅមកនៅពេលប្រាស្រ័យទាក់ទងគ្នា។ ពេលធ្វើខុសឆ្គង ដល់ជនណាម្នាក់ដោយអចេតនា ក្នុងរបៀបសុជីវធម៌របស់ខ្មែរ ក៏ដូចជាសុជីវធម៌របស់ជនជាតិបរទេស គេពោលពាក្យថា ខ្ញុំសុំ ទោស។ ឯអ្នកដែលត្រូវគេសុំទោស តែងមានសុជីវធម៌តបវិញ ថា មិនអីទេ។ ឧទាហរណ៍នេះបញ្ជាក់ថា គេមានសុជីវធម៌ គឺ ការរស់នៅមានសភាពសមរម្យចេះអត់ឱនឲ្យដល់គ្នាទៅវិញទៅ មក។ ការគួរសមនឹងគ្នានេះ ជាប្រពៃណីដ៏ល្អរបស់មនុស្សជាតិ ដែលមានអារ្យធម៌ខ្ពស់ជាងសត្វតិរច្ឆាន។ ដូចជាជនជាតិខ្មែរ តែងមានការគួរសមនឹងគ្នា នៅពេលជួបគ្នាលើកដៃសំពះសួរ ហើយពោលថា ខ្ញុំសុំជំរាបសួរ។ ឯអ្នកដែលគេលើកដៃសំពះ ក៏សំពះតបវិញ ហើយពោលថាលើកដៃថ្វាយព្រះ។ លក្ខណៈ

នេះ ពុំមែនជាអំពើថោកទាបឬមិនជឿនលឿននោះទេ តែជាអំពើរបស់ជនជាតិមានពូជអម្បូរថ្លៃថ្នូរខ្ពង់ខ្ពស់ជឿនលឿនដែលផ្ទុយគ្នាអំពីការឥតពូជសម្បូរវិញទេ។ កូនចៅប្រុសស្រីខ្មែរតែងគោរពឪពុកម្ដាយរបស់ខ្លួន គោរពចាស់ព្រឹទ្ធាចារ្យ គោរពព្រះសង្ឃព្រះពុទ្ធសាសនា។ ការគោរពនេះ គឺការសំដែងការកោតក្រែងនិងមានភក្តីភាព។ នៅកន្លែងជាច្រើនដែលត្រូវមានសុជីវធម៌ ដូចជាសុជីវធម៌ក្នុងពេលស្ដាប់សន្និសីទអ្វីមួយ សុជីវធម៌ក្នុងពេលធ្វើពិធីកម្មក្នុងសាសនាជាដើម។ នេះជាអត្ថន័យដោយសង្ខេបនៃពាក្យថា សុជីវធម៌។

## ២. សីលធម៌

ពាក្យថា **សីលធម៌** ប្រែថា ច្បាប់ដែលមានប្រក្រតីខាងល្អបានដល់ច្បាប់សំរាប់រៀបចំចរិយាមារយាទឲ្យខ្ពង់ខ្ពស់ថ្លៃថ្នូរ គឺការពុំប្រព្រឹត្តធ្វើអំពើអាក្រក់ដោយកាយនិងវាចា។ ពាក្យថាសីលធម៌នេះ បើតាមអត្ថន័យពួកបស្ចឹមប្រទេសឲ្យន័យថា សីលធម៌គឺជាវិទ្យាសាស្ត្រដែលបង្រៀនរបៀបអនុវត្តដោយជៀសវាងអំពើអាក្រក់។ សីលធម៌មានន័យជម្រៅជាងសុជីវធម៌ គឺសីលធម៌មានន័យអនុវត្តផ្លូវកាយនិងវាចារបស់មនុស្សឲ្យបានល្អ ជៀសវាងការបៀតបៀនអ្នកដទៃ។ សីលធម៌របស់សាសនា

នៃសង្គមខ្លះ ហាមមិនឲ្យបៀតបៀននិងសម្លាប់មនុស្សជាតិទូទៅ តែសត្វតិរច្ឆានពុំហាមឡើយ។ ចំណែកសង្គមអ្នកកាន់ព្រះពុទ្ធសាសនា ហាមទាំងមនុស្សទាំងសត្វមិនឲ្យសម្លាប់ ដូចមាននិយាយនៅក្នុងសិក្ខាបទទី១នៃសីល៥ គឺជាសីលធម៌មានន័យទូលាយនិងមានកម្រឹតខ្ពស់។ ការពុំមានសីលធម៌នាំឲ្យមនុស្សបៀតបៀនគ្នា និងបង្ហូរឈាមគ្នា។ ការមានសីលធម៌ គឺការគោរពសិទ្ធិមនុស្សនេះឯង។ នេះជាអត្ថន័យសង្ខេបនៃពាក្យថាសីលធម៌។

## ៣. ទំនាក់ទំនងរវាងសុជីវធម៌និងសីលធម៌

ដើម្បីធ្វើឲ្យមនុស្សមានគុណសម្បត្តិខ្ពង់ខ្ពស់ថ្លៃថ្នូរត្រូវមានធម៌ទាំងពីរនេះ គឺត្រូវមានសុជីវធម៌ផងសីលធម៌ផង។ បើមានតែសីលធម៌ខ្វះសុជីវធម៌ មនុស្សនោះពុំបៀតបៀនអ្នកដទៃ ប៉ុន្តែខ្វះការគួរសមទៅរកអ្នកដទៃនៅពេលដែលជួបប្រាស្រ័យទាក់ទងគ្នា ដែលជានាទីរបស់សុជីវធម៌។ ការពុំមានការគួរសមតាមប្រពៃណីទំនៀមទម្លាប់ គេឲ្យគុណវិបត្តិថាជាមនុស្សឈ្លើយសង្គម។ បើមានតែសុជីវធម៌ខ្វះសីលធម៌វិញ នោះមានគុណវិបត្តិធ្ងន់ណាស់ គឺល្អតែអាការៈខាងក្រៅប៉ុន្តែប្រព្រឹត្តអាក្រក់។ ដូចជាចោរជាអ្នកលួចទ្រព្យសម្បត្តិអ្នកដទៃ ប៉ុន្តែមានសំដីទន់

ភ្លន់ មានកាយវិការរាក់ទាក់អ្នកដទៃ។ មនុស្សគ្មានសីលធម៌ គេចាត់ទុកថាជាមនុស្សសត្រូវរបស់សង្គម ព្រោះនឹងបង្ករឿង ហេតុធ្វើឲ្យគេវិនាសក្នុងពេលណាមួយ។ មួយទៀត ខ្លះឲ្យន័យ ថា សុជីវធម៌ ក៏មានន័យប្រហែលគ្នានឹងសីលធម៌ដែរ ព្រោះ សុជីវធម៌ដែលមានន័យថារស់នៅសមរម្យ គឺរស់នៅសម្រប សម្រួលជាមួយសង្គម ស្របតាមប្រពៃណីទំនៀមទម្លាប់ គឺការ មិនបៀតបៀនសង្គមហ្នឹងឯង។ សីលធម៌និងសុជីវធម៌នេះ ជា ផ្នែកគុណសម្បត្តិខាងចរិយា។ បន្ថែមទៅលើធម៌ទាំងពីរនេះ ត្រូវមានគុណធម៌មួយទៀតគឺវិជ្ជាសម្បត្តិ។ ការមានចំណេះចេះ ដឹងនិងមានចរិយាល្អ នោះជាគុណសម្បត្តិដ៏ខ្ពស់ខ្ពស់របស់ មនុស្ស។ ជនជាតិកម្ពុជាគ្រប់ឋានៈគ្រប់ភេទទាំងអ្នកកាន់អំ ណាចទាំងប្រជាពលរដ្ឋ បើនាំគ្នាបណ្តុះឲ្យមានគុណធម៌ទាំង នេះ នោះប្រទេសកម្ពុជានឹងមានសន្តិភាពនិងវឌ្ឍនភាព ព្រោះ ការកសាងធនធានមនុស្សជាកត្តាសំខាន់បំផុតក្នុងការកសាង សង្គមមនុស្សឲ្យបានចំរើនលូតលាស់។

 លលលលល

# ៧- នាយកធម៌

# ធម៌សំរាប់អ្នកដឹកនាំ

ប្រភេទនៃធម៌ដែលសំរាប់ធ្វើជាមេគេ ឬជានាយកលើគេ មានជាច្រើនយ៉ាង តែក្នុងពេលនេះ សូមអធិប្បាយចំពោះធម៌ដែលសំរាប់ធ្វើជាមេឬធ្វើជានាយកគេមួយប្រភេទ ដែលដឹកនាំសំរាប់ការរស់នៅក្នុងក្រុមឬសង្គមមួយ ឲ្យមានការឈ្លាសវៃនិងប៉ិនប្រសប់ក្នុងការដឹកនាំ ដើម្បីសេចក្តីសុខចំរើនដល់អ្នកដែលនៅក្រោមបង្គាប់។ ធម៌នេះហៅថា **នាយកធម៌** ប្រែថាធម៌សំរាប់អ្នកដឹកនាំយកទៅប្រតិបត្តិ មាន៦យ៉ាងគឺៈ

**១. ខមា** ប្រែថា មានសេចក្តីអត់ធន់ គឺធ្វើជានាយកលើគេត្រូវមានសេចក្តីអត់ធន់ចំពោះការលំបាកគ្រប់យ៉ាងតាមផ្លូវកាយនិងផ្លូវចិត្ត ជាពិសេសចំពោះការរិះគន់ពីអ្នកដទៃ ពុំមានការក្រេវក្រោធរហូតមានគំនិតព្យាបាទចំពោះអ្នករិះគន់ដើម្បីស្លាបនានោះឡើយ។

**២. ជាគរិយ** ប្រែថា មានសេចក្តីភ្ញាក់រលឹករឿយៗ គឺធ្វើជានាយកលើគេត្រូវមានការឈ្លាសវៃ មានស្មារតីរស់រវើកជានិច្ច មានគំនិតផ្តួចផ្តើមបង្កើតផែនការ រិះរកមធ្យោបាយធ្វើយ៉ាង

ណាឲ្យក្រុមឬសង្គមរបស់ខ្លួនបានលូតលាស់ចំរើន គឺមិនស្លាប់គំនិតដូចមនុស្សដេកលក់ ត្រូវដឹងមុខងារនាទីរបស់ខ្លួនថា ថ្ងៃនេះត្រូវធ្វើអ្វីហើយថ្ងៃស្អែកត្រូវធ្វើអ្វីទៀតជាដើម។ អ្នកដឹកនាំជាតិក៏ដូចគ្នា ត្រូវមានស្មារតីរស់រវើកនិងឈ្លាសវៃបំផុតក្នុងការការពារឯករាជ្យអធិបតេយ្យនិងបូរណភាពទឹកដី។ បើមានជម្លោះផ្ទៃក្នុងត្រូវដោះស្រាយដោយសន្តិវិធី ឲ្យមានឯកភាពជាតិ ការពារកុំឲ្យមានការជ្រៀតជ្រែកពីខាងក្រៅ។

៣. **ឧដ្ឋានៈ** ប្រែថា មានសេចក្តីឧស្សាហ៍ព្យាយាម គឺធ្វើជានាយកដឹកនាំត្រូវមានសេចក្តីព្យាយាមយ៉ាងខ្លាំងក្លាឲ្យជាគំរូដល់អ្នកដទៃទៀត ជាពិសេសឲ្យជាគំរូដល់សហការីរបស់ខ្លួន។

៤. **សំវិភាគៈ** ប្រែថា ការចែករំលែក អ្នកធ្វើជាមេដឹកនាំត្រូវចេះចែករំលែកគ្រឿងចិញ្ចឹមជីវិត ដូចជាប្រដាប់ប្រដាប្រើប្រាស់ ចំណីអាហារបរិភោគជាដើម ដល់អ្នកធ្វើការជាមួយឲ្យសមរម្យល្មមរស់នៅបានផង។ មួយទៀត ត្រូវចាត់ចែងការងារឲ្យសមាជិកធ្វើឲ្យស្របទៅតាមកម្លាំងកាយនិងកម្លាំងសមត្ថភាព។ បើនិយាយពីក្រុមហ៊ុនវិញ ត្រូវផ្តល់ប្រាក់ខែឲ្យកម្មករឲ្យបានសមរម្យ បើបានចំណេញច្រើនត្រូវដំឡើងប្រាក់បៀវត្សរ៍

បន្ថែមទៀតដល់កម្មករ។ ត្រូវចេះលើកទឹកចិត្តកម្មករដោយផ្តល់ប្រាក់បំណាច់ឲ្យកម្មករម្តងម្កាលផង។

**៥. ទយា** ប្រែថា មានចិត្តអាណិតអាសូរ គឺនាយកដឹកនាំ ឬមេក្រុមហ៊ុនមានចិត្តអាណិតអាសូរដល់សហការីឬកម្មករ ដែលធ្វើការ ឲ្យដូចជាឪពុកម្តាយស្រឡាញ់កូន។ បើកម្មករមានជម្ងឺត្រូវឲ្យសម្រាកហើយបញ្ជូនទៅមន្ទីរពេទ្យ កុំប្រើទាំងឈឺ។ បើកម្មករមានវិបត្តិផ្លូវចិត្ត ត្រូវជួយណែនាំនិយាយពន្យល់ហេតុផលឲ្យមានកម្លាំងផ្លូវចិត្តឡើងវិញ។

**៦. ឥក្ខនា** ប្រែថា ការពិនិត្យមើលកិច្ចការដែលបានធ្វើ ដើម្បីកែលំអឲ្យបានប្រសើរឡើងទៀត។ ការបានចំរើនលូតលាស់នៃសង្គមមួយឬក្រុមហ៊ុនមួយ ពុំមែនត្រឹមតែផែនការដែលដាក់ចេញឲ្យអនុវត្តប៉ុណ្ណោះទេ គឺនៅលើអ្នកអនុវត្តដែលជាសមាជិកឬកម្មករពេញចិត្តអនុវត្តផង។ ដើម្បីឲ្យសមាជិកឬកម្មករធ្វើសហការដោយការរីករាយផង លុះត្រាតែមានលក្ខខណ្ឌការងារបានល្អ ពុំរំលោភលើសិទ្ធិសមាជិកឬកម្មករ។ កាលណាសមាជិកឬកម្មករធ្វើសហការដោយពេញចិត្តនិងដោយសារតែខ្លួនបានទទួលកម្រៃបន្ថែម នៅពេលដែលលទ្ធផលនៃការងារបានលូតលាស់ ទើបក្រុមហ៊ុនជាដើមនោះ កាន់តែមានវឌ្ឍន

ភាពនិងស្ថេរភាព។ បញ្ហាជាតិក៏ដូចគ្នា លុះត្រាតែប្រជាពលរដ្ឋធ្វើសហការជាមួយរដ្ឋាភិបាល ទើបធ្វើឲ្យប្រទេសមានសន្តិភាពវឌ្ឍនភាពនិងស្ថេរភាព។

នាយកធម៌ទាំង៦នេះ ជាធម៌សំរាប់ការដឹកនាំតូចធំទាំងផ្នែកសង្គមកិច្ចវប្បធម៌ទាំងផ្នែកនយោបាយត្រូវអនុវត្ត។ ចំណែកទសពិធរាជធម៌១០យ៉ាងនោះ សំរាប់ការដឹកនាំនយោបាយជាន់ខ្ពស់។

ꕤꕤꕤꕤꕤ

# ៨- ព្រះវេស្សន្តរជាគំរូ ដល់អ្នកប្រជាធិបតេយ្យសម័យទំនើប

**ព្រះវេស្សន្តរ** ជារឿងជាតកទី១០នៃការកសាងទានបារមីនៃព្រះពោធិសត្វ ដើម្បីឲ្យបានត្រាស់ជាព្រះពុទ្ធគឺ**ព្រះសមណគោតម**។ក្នុងវគ្គមួយនៃផ្ទៃរឿងនិយាយថា ព្រះវេស្សន្តរបានត្រូវប្រជារាស្ត្រដេញចេញពីព្រះនគរ តាមរយៈការធ្វើបាតុកម្មមួយដោយប្រឆាំងនឹងព្រះអង្គអំពីការដាក់ទានដំរីដែលប្រជារាស្ត្រយល់ថាជាដំរីមង្គលរបស់ប្រទេសឲ្យដល់ពួកព្រាហ្មណ៍។ ក្នុងពេលនោះ ព្រះវេស្សន្តរបានធ្វើតាមសំណូមពររបស់ប្រជារាស្ត្រព្រះអង្គ។ ការសម្រេចព្រះទ័យបែបនេះ ចាត់ទុកថា ព្រះវេស្សន្តរពោធិសត្វមានឧត្តមគតិខ្ពង់ខ្ពស់ណាស់ក្នុងការគោរពតាមឆន្ទៈរបស់ប្រជារាស្ត្រ ដោយពុំប្រឆាំងនឹងមតិរបស់ប្រជារាស្ត្រ សុខចិត្តទៅរស់នៅក្នុងព្រៃគិរីវង្គត ដូចពាក្យដែលព្រះអង្គបានពោលក្នុង**កណ្ឌហេមពាន្ត**សុំអនុញ្ញាតពីប្រជារាស្ត្រថា យើងនឹងទៅតាមផ្លូវរបស់ក្សត្រដែលធ្វើខុស សូមអ្នកទាំងឡាយអត់ទោសបង្អង់ឲ្យយើងមួយយប់មួយថ្ងៃសិន ទំរាំយើងឲ្យទានស្រេច។ ក្នុងព្រះសកម្មភាពដ៏អស្ចារ្យនេះ យើងគួរលើកឡើងវិភាគថា ហេតុអ្វីបានជាពេលនោះ ព្រះអង្គពុំប្រើកម្លាំងទ័ពដើម្បីបង្ក្រាបប្រជា

រាស្ត្រដែលធ្វើបាតុកម្មដេញព្រះអង្គចេញពីព្រះនគរ ព្រោះពេលនោះ ព្រះអង្គមានអំណាចគ្រប់គ្រាន់ជាមួយព្រះបាទ**ស្រីសញ្ជ័យ**ជាព្រះបិតា។ តាមការសង្កេត ធម្មតាព្រះពោធិសត្វតែងតែកសាងអំពើជាកុសល តែងជៀសវាងការបៀតបៀនជានិច្ច។ យ៉ាងណាមិញ ព្រះពោធិសត្វវេស្សន្តរដោះស្រាយវិបត្តិនេះ **ដោយសន្តិវិធី ព្រោះព្រះអង្គយល់ថា ការបង្ក្រាបដោយធម៌ហឹង្សាពុំបានជោគជ័យឡើយ ផ្ទុយទៅវិញ នឹងរឹតតែបន្ថែមកំហឹងរបស់ប្រជារាស្ត្រឲ្យកើតមានកាន់តែខ្លាំងឡើងថែមទៀត ហើយជាអំពើពាលខុសពីលក្ខណៈរបស់គតិបណ្ឌិតផង**។ម៉្យាងទៀត ព្រះអង្គពុំចង់ឲ្យប្រជារាស្ត្រមានទុក្ខព្រួយដោយសារតែព្រះអង្គ។ ដូច្នេះឃើញថា ព្រះវេស្សន្តរបានគោរពឆន្ទៈរបស់ប្រជារាស្ត្រ បានគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ជាភ័ស្តុតាងព្រះអង្គបានធ្វើតាមឆន្ទៈរបស់ប្រជារាស្ត្រ ព្រមទាំងបានសុំទោសប្រជារាស្ត្រជាសាធារណៈទៀតផង។

ដំណោះស្រាយរបស់ព្រះវេស្សន្តរ គឺជាដំណោះស្រាយដោយសន្តិវិធីជាមួយប្រជារាស្ត្រព្រះអង្គ។ អ្នកដឹកនាំខ្មែរបច្ចុប្បន្ន និងទៅអនាគត គួរហាត់រៀនសិក្សាតាមឧត្តមគតិរបស់ព្រះវេ-

ស្សន្តរនេះ គឺព្រះអង្គពុំបានធ្វើឲ្យប្រជារាស្ត្រច្បាំងគ្នាដោយសារតែផលប្រយោជន៍ឬកំហឹងផ្ទាល់ខ្លួនព្រះអង្គឡើយ។ ព្រះអង្គបានចែកដាច់ពីគ្នារវាងប្រយោជន៍ផ្ទាល់ខ្លួននិងប្រយោជន៍ជាតិ ហើយបានទទួលកំហុសរបស់ព្រះអង្គជាផ្លូវការផង។

រឿងព្រះវេស្សន្តរពោធិសត្វ ជាគំរូអ្នកដឹកនាំដែលមានឧត្តមគតិខ្ពស់មិនធ្វើឲ្យប្រជារាស្ត្រនិងប្រជារាស្ត្របង្ហូរឈាមគ្នា។ បុព្វហេតុដែលនាំឲ្យប្រជារាស្ត្រកើតទុក្ខមិនសុខចិត្តបានធ្វើបាតុកម្មប្រឆាំងនឹងព្រះអង្គ ដោយសារព្រះអង្គដាក់ទានដំរីមង្គលដល់ពួកព្រាហ្មណ៍។ ដូច្នេះ ដើម្បីរំងាប់កំហឹងរបស់ប្រជារាស្ត្រ ព្រះអង្គបានយកទឹកទៅលត់ គឺសុខចិត្តធ្វើតាមសំណូមពររបស់ប្រជារាស្ត្រ ទៅរស់នៅក្នុងព្រៃគិរីវង្កតទ្រាំលំបាកវេទនានៅក្នុងព្រៃ ដើម្បីប្រជារាស្ត្រស្ងប់ផ្លូវចិត្តនិងធ្វើឲ្យប្រទេសព្រះអង្គស្ថិតនៅជាប្រក្រតីឡើងវិញ។ ព្រះវិចារណញ្ញាណដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គនេះ ក្នុងទីបំផុតរឿង ព្រះអង្គត្រូវប្រជារាស្ត្រនាំគ្នាទៅហែព្រះអង្គឲ្យត្រឡប់មកនគរវិញ ដែលហៅថា **នគរកណ្ឌ** ដែលនាំឲ្យព្រះអង្គបំពេញទានបារមីជាបន្តទៀត។ ទំនាស់មិនប្រើហឹង្សានេះបានទទួលជោគជ័យទាំងខ្លួនព្រះអង្គផ្ទាល់ទាំងប្រជារាស្ត្រ ហើយប្រទេសរបស់ព្រះអង្គនៅតែមានគ្រឹះរឹងមាំក្នុងសុខសន្តិ

ភាព។ ដូច្នេះ **ព្រះវេស្សន្តរជាគំរូនៃអ្នកប្រជាធិបតេយ្យសម័យទំនើប ព្រោះព្រះអង្គធ្វើតាមមតិរបស់ប្រជារាស្ត្រ។**

**ៜៜៜៜៜ**

# ៩- ការមិនបៀតបៀនអ្នកដទៃ ដោយយកខ្លួនជាគ្រឿងឧបមា

គាថា១បទនៅក្នុងគម្ពីរព្រះពុទ្ធសាសនាពោលថា **សព្វេ តសន្តិ ទណ្ឌស្ស សព្វេសំ ជីវិតំ បិយំ អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ** ប្រែថា សត្វទាំងឡាយសុទ្ធតែតក់ស្លុតចំពោះអាជ្ញាគ្រប់ៗគ្នាទាំងអស់ សត្វទាំងឡាយសុទ្ធតែស្រឡាញ់ជីវិតគ្រប់ៗគ្នាទាំងអស់ ដូច្នេះបុគ្គលគប្បីធ្វើខ្លួនជាគ្រឿងឧបមា ហើយមិនគួរវាយប្រហារដោយខ្លួនឯង មិនគួរប្រើអ្នកដទៃឲ្យវាយប្រហារនូវសត្វដទៃឡើយ។

ពាក្យថា សត្វទាំងឡាយសុទ្ធតែតក់ស្លុតចំពោះអាជ្ញាគ្រប់ៗគ្នាទាំងអស់ បានសេចក្តីថា ទាំងមនុស្សទាំងសត្វតិរច្ឆានដែលមានជីវិត សុទ្ធតែមានការភ័យខ្លាចចំពោះអាជ្ញា ការវាយដោយដំបង ចាក់ដោយកាំបិត បាញ់ដោយកាំភ្លើងជាដើមគ្រប់ៗគ្នា។ ពាក្យថា សត្វទាំងឡាយ សុទ្ធតែស្រឡាញ់ជីវិតគ្រប់ៗគ្នា បានសេចក្តីថា សត្វទាំងឡាយសុទ្ធតែចង់រស់នៅពុំចង់ស្លាប់ ចង់មានអាយុវែង មិនចង់មានរោគាព្យាធិ ទោះបីជីវិតស្ថិតនៅក្នុងវ័យជរានិងពិការ ក៏សុទ្ធតែចង់រស់មិនចង់ស្លាប់ គឺមានចិត្ត

ជាប់នឹងជីវិតរបស់ខ្លួនជានិច្ច។ ពាក្យថា ដូច្នេះ បុគ្គលគប្បីធ្វើខ្លួនឲ្យជាគ្រឿងឧបមា ហើយមិនគួរវាយប្រហារដោយខ្លួនឯង មិនគួរប្រើអ្នកដទៃឲ្យវាយប្រហារនូវសត្វដទៃឡើយ។ បានសេចក្តីថា មុននឹងបៀតបៀនមនុស្សសត្វដទៃ ត្រូវប្រៀបធៀបមកខ្លួនថា ខ្លួនស្រឡាញ់ជីវិតខ្លួន មិនចង់ឲ្យអ្នកដទៃវាយប្រហារ មិនចង់ឲ្យអ្នកដទៃសម្លាប់ជាដើម មនុស្សសត្វទាំងឡាយដទៃទៀតក៏មានបំណងនេះដូចគ្នា ដូច្នេះពុំគួរបៀតបៀនគ្នាដោយមធ្យោបាយណាមួយឡើយ។ ព្រះពុទ្ធសាសនាសំដែងថា មនុស្សកើតមកមានអាយុខ្លីឆាប់ស្លាប់ទៅវិញ ព្រោះកាលពីជាតិមុនបានសម្លាប់សត្វបំបាត់ជីវិតគេ, កើតមកមានរោគច្រើនមានជម្ងឺប្រចាំកាយ ព្រោះកាលពីជាតិមុនបៀតបៀនសត្វឬបៀតបៀនមនុស្សធ្វើឲ្យគេរងទុក្ខវេទនាតាមផ្លូវកាយឬតាមផ្លូវចិត្ត, ក្រុមគ្រួសារម្តាយឪពុកប្តីប្រពន្ធកូនចៅឆាប់ព្រាត់ប្រាសបាក់បែកគ្នា មកពីជាតិមុននោះពង្រាត់ពង្រះសត្វ ធ្វើឲ្យមេបាកូនចៅគេបែកបាក់គ្នា។

បើពុទ្ធសាសនិកជនខ្មែរគ្រប់ឋានៈគោរពតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដូចពោលមកនេះ នោះការបៀតបៀនគ្នាពុំមានឡើយ។ សង្គមមួយឬប្រទេសមួយដែលពុំមានការបៀត

បៀនគ្នា សង្គមនោះនឹងមានសុខស្ងប់។ ត្រង់ព្រះពុទ្ធមិនឲ្យមនុស្សសត្វបៀតបៀនគ្នានេះហើយ ដែលទុកជាមូលដ្ឋាននៃការគោរពសិទ្ធិមនុស្ស។ ប្រជាពលរដ្ឋខ្មែរមានភ័ព្វសំណាងណាស់ដែលបានទទួលកាន់យកព្រះធម៌របស់ព្រះពុទ្ធ ដែលជាធម៌ដ៏បរិសុទ្ធសំរាប់ញ៉ាំងអ្នកប្រតិបត្តិតាម ទទួលសេចក្តីសុខចំរើនក្នុងជីវភាពប្រចាំថ្ងៃនិងជីវិតអនាគត។ ព្រះធម៌ជាច្បាប់ព្រះពុទ្ធសាសនានេះ ជាជំនួយសំខាន់ណាស់សំរាប់ផ្លូវអាណាចក្ររបស់ប្រទេសកម្ពុជា បានជាមានពាក្យខ្មែរថា ផ្លូវពុទ្ធចក្រនិងអាណាចក្រត្រូវដើរទៅជាមួយគ្នា ទើបធ្វើឲ្យប្រទេសកម្ពុជាបានសុខសន្តិភាព។

ឈឈឈឈឈ

# ១០- ទំនើខ្វះការពិចារណានាំឲ្យខូចប្រយោជន៍
## - រឿងអ្នកចំការពីរនាក់
## - រឿងសត្វតោពីរ

ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា ក៏ដូចជាពាក្យប្រៀនប្រដៅរបស់ចាស់បូរាណខ្មែរ បានរំលឹកថា មុននឹងសម្រេចចិត្តធ្វើអ្វីមួយ ក្នុងបញ្ហាគ្រួសារក៏ដូចជាបញ្ហាសង្គមប្រទេសជាតិ ត្រូវពិចារណាឲ្យបានល្អិតល្អន់ឲ្យយល់ច្បាស់ជាមុនសិន។ ទំនើខ្វះការពិចារណាអាចអនុវត្តខុស នាំខូចប្រយោជន៍ហើយសោកសៅជាក្រោយ។ ក្នុងន័យនេះ មានរឿងក្នុងគតិលោករបស់លោកសុត្តន្តប្រីជាឥន្ទ ទោះបីដាក់ចំណងជើងសៀវភៅថា គតិលោក ក៏មានទាក់ទងនឹងគតិធម៌ដែរ។ រឿងទាំងនោះ ទោះបីរឿងខ្លះយកសត្វធ្វើជាតួអង្គក៏ដោយ ក៏បានជាគតិប្រសើរណាស់ សំរាប់អប់រំសង្គមមនុស្សពិសេសសង្គមខ្មែរឲ្យឈ្លាសវៃក្នុងការរស់នៅ ព្រោះសត្វជាតួអង្គទាំងនោះ ជាតំណាងនៃមនុស្សនិងសង្គមមនុស្សហ្នឹងឯង។

ដូចរឿងអ្នកចំការពីរនាក់ប្ដីប្រពន្ធមានចិត្តសោកស្ដាយដោយបានសម្លាប់សត្វស្កា ដោយយល់ខុសថា សត្វស្កានោះ

បានខាំសម្លាប់កូនរបស់ខ្លួន មកពីមានកំហឹងខ្វះការពិចារណា។ ដំណើររឿងដោយសង្ខេបថា បុរសនិងនារីពីរនាក់ប្តីប្រពន្ធជាអ្នកចំការបានចិញ្ចឹមសត្វស្កាមួយ។ ថ្ងៃមួយ ពីរនាក់ប្តីប្រពន្ធបានចេញទៅធ្វើការខាងក្រៅ ទុកកូនតូចខ្ចីនៅក្នុងអង្រឹងនិងសត្វស្កានោះឲ្យចាំផ្ទះ។ ពេលដែលចេញផុតទៅ មានពស់មានពិសមួយដោយផុំក្លិនទឹកដោះក្នុងមាត់ទារក បានលូនចូលទៅក្នុងអង្រឹងចឹកទារកនោះស្លាប់ទៅ។ ពេលឮសូរទារកនោះយំ សត្វស្កាបានបោលយ៉ាងលឿនតម្រង់ទៅអង្រឹង ឃើញពស់ចឹកទារកនោះស្លាប់ ក៏ធ្វើការប្រយុទ្ធយ៉ាងអង់អាចជាមួយនឹងពស់រហូតខាំពស់នោះស្លាប់ទៅ ហើយខាំអូសទាញយកមកទុកក្រោមជើងម៉ា។ ពេលបុរសប្តីប្រពន្ធត្រឡប់មកវិញ សត្វស្កាបានរត់ឆ្លេឆ្លាចុះឡើងហាក់ដូចជាចង់ថ្លែងប្រាប់ម្ចាស់អំពីព្រឹត្តិការណ៍ពេលដែលខ្លួនចាំផ្ទះ។ ម្ចាស់ផ្ទះប្តីប្រពន្ធឃើញឈាមនៅនឹងមាត់ស្កាកើតមានសេចក្តីសង្ស័យ ក៏រត់ទៅមើលកូនក្នុងអង្រឹង ឃើញកូនស្លាប់ដោយមានស្នាមជាំត្រង់ភ្លៅកូន ក៏សន្និដ្ឋានខុសថា សត្វស្កាបានខាំកូនរបស់ខ្លួន ក៏កើតកំហឹងយកដំបងវាយសត្វស្ការហូតដល់ស្លាប់ទៅ។ ងាកចុះងាកឡើងស្រាប់តែឃើញពស់ដែលស្លាប់នៅក្រោមជើងម៉ា ក៏កើតការសង្ស័យ

ក៏ស្ទុះទៅពិនិត្យមើលស្នាមភ្លៅកូនដែលជាំម្តងទៀត ទើបដឹងច្បាស់ថា ជាស្នាមពស់ចឹក ពុំមែនជាស្នាមស្កាខាំឡើយ ក៏កើតរន្ធត់ក្នុងចិត្ត យំអាណិតកូនផង សោកស្តាយសត្វស្កាដែលខ្លួនសម្លាប់ខ្វះការពិចារណាឲ្យបានម៉ត់ចត់ ដែលជាសត្វឥតទោស ជាសត្វមានគុណការពារកូនខ្លួនផង។ រឿងនេះ បានឲ្យមេរៀនថា អំពើគ្រប់យ៉ាងដែលគេធ្វើទាំងកំហឹងមិនបានពិចារណាឲ្យបានច្បាស់លាស់ជាមុន តែងមានការភ្លាត់ខុសខូចប្រយោជន៍ ហើយមានការសោកស្តាយជាក្រោយ។

រឿងនេះ បានឲ្យមេរៀនថ្លៃថ្លាណាស់ សំរាប់ជនជាតិខ្មែរក្នុងបច្ចុប្បន្ននិងទៅអនាគតទៀត កុំឲ្យសម្លាប់គ្នាដោយខ្វះការពិចារណា ព្រោះតាំងពីក្រោយសម័យមហានគរ ខ្មែរមានការទាស់ទែងខ្វែងគំនិតគ្នាជាញឹកញាប់ ហើយម្ខាងៗពឹងបរទេសឲ្យជួយបង្ក្រាបឈាមខ្មែរគ្នាឯង។ ទីបំផុត ទឹកដីខ្មែរបានរួញតូចដូចសព្វថ្ងៃនេះ។ អនាគត បើមិនប្រុងប្រយ័ត្នទេ ទឹកដីនឹងរួញតូចតទៅទៀត។

មានរឿងមួយទៀតនិទានថា មានសត្វភេពីរ ភេមួយរកស៊ីក្នុងទឹកជ្រៅ ភេមួយទៀតរកស៊ីក្នុងទឹករាក់។ ថ្ងៃមួយភេទាំងពីរចាប់បានត្រីរ៉ស់មួយ ចែកគ្នាឯងពុំដាច់ស្រេច ក៏កើតជាជម្លោះ

ហើយសម្រេចនាំគ្នាទៅប្តឹងសត្វចចកឲ្យធ្វើជាចៅក្រមកាត់សេចក្តីឲ្យខ្លួន។ ឆ្កែចចកក៏កាត់សេចក្តីដោយកាត់ត្រីរ៉ស់នោះជាបីភាគ ខាងក្បាលឲ្យទៅភេដែលមុជទឹកជ្រៅ ខាងកន្ទុយឲ្យទៅភេដែលមុជទឹករាក់ ចំណែកភាគកណ្តាលចចកស៊ីខ្លួនឯង។ ភេទាំងពីរនឹកតូចចិត្តណាស់ ដោយឃើញចចកស៊ីត្រង់ភាគកណ្តាលដែលសុទ្ធតែសាច់។ ឯភេដែលបានត្រង់កន្ទុយនឹកតូចចិត្តជាងគេ មិនដឹងធ្វើអ្វីនឹងចចកបាន បែរមកច្រណែនភេគ្នាឯងដែលបានត្រង់ក្បាល។ កើតទុក្ខពុំសុខចិត្ត ភេទាំងពីរក៏នាំគ្នាទៅប្តឹងខ្លាត្រីឲ្យកាត់សេចក្តី។ ខ្លាត្រីកាត់សេចក្តីដោយយកជញ្ជីងត្រាជូមកថ្លឹង ក្បាលត្រីធ្ងន់ជាង ខ្លាត្រីខិនស៊ីសាច់អមក ដល់ថ្លឹងម្តងទៀតខាងកន្ទុយធ្ងន់ជាង ខ្លាត្រីខិនស៊ីសាច់គល់កន្ទុយ ខ្លាត្រីក្លែងថ្លឹងមិនឲ្យស្មើ ស៊ីទៅស៊ីមកទាល់តែអស់សាច់រេចនៅសល់តែឆ្អឹងទាំងសងខាង ទើបថ្លឹងក្រោយឲ្យស្មើគ្នា ហើយខ្លាត្រីពោលទៅភេទាំងពីរថា ហ្ននាំគ្នាយកទៅ យកណាមួយក៏បាន ខ្ញុំថ្លឹងឲ្យស្មើគ្នាហើយគ្មានលើសខ្វះទេ យុត្តិធម៌ហើយ។ ភេទាំងពីរឃើញខ្លាត្រីក្លែងថ្លឹងស៊ីសាច់អស់ដូច្នេះ ក៏នឹកតូចចិត្តទ្វេឡើងថែមទៀត នឹកស្តាយត្រីរ៉ស់ ដោយគិតខុសបែកសាមគ្គីគ្នា ចង់លោភយកតែឯងរហូតដល់ខានស៊ីទាំងអស់គ្នា ហើយក៏ដើរ

ចេញរៀងខ្លួនទៅ។ ពាក្យកាព្យថា «ភេអើយភេពីរ ខេខឹងមមី បែកក្តីសាមគ្គី ព្រោះលោភតែឯង មិនបែងចែកគ្នា ទៅប្តឹងដល់វា ចចកឲ្យចែក។ ធម្មជាតិចចក ជាសត្វលៃលក វាយយក ចំណែក កណ្តាលសាច់ច្រើន ចំរើនអ្នកចែក ចុងដើមបំបែក បានភេទ្វេហា។ ក្រោយមកភេខឹង ពាំត្រីទៅប្តឹង ខ្លាត្រីទៀតណា ខ្លាថ្លឹងត្រាជូ ស៊ីសាច់ផងណា ទំរាំស្មើគ្នា នៅសល់តែឆ្អឹង»។

រឿងនេះ មានឧត្តមគតិពីរយ៉ាងគឺ ទីមួយ ចៅក្រមកាត់សេចក្តីអយុត្តិធម៌ស៊ីសំណូកពុករលួយ ដែលធ្វើកូនក្តីទាំងសងខាង ខាតបង់ទាំងអស់គ្នា ឯប្រយោជន៍ទាំងអស់បានទៅលើចៅក្រម គឺឈ្លោះគ្នាបានចំណេញទៅលើចៅក្រម។ ដូច្នេះ រឿងនេះ ចៅក្រមខ្មែរក្តី អ្នកមានជម្លោះគ្នាក្តី គប្បីយករឿងនេះទៅពិចារណា។ ទីពីរ បើនិយាយដល់ថ្នាក់ជាតិវិញ ខ្មែរនិងខ្មែរទាស់គ្នា ចំណេញទៅបរទេសជិតខាងដែលចង់បានទឹកដីខ្មែរ។

# ១១- ទោសនៃការលេងល្បែងស៊ីសង

ការលេងល្បែងដែលមានទោស គឺសំដៅយកល្បែងស៊ីសង ដាក់ប្រាក់កាសឬដាក់វត្ថុផ្សេងៗ។ បើលេងកីឡាហាត់ប្រាណ លេងកីឡាជាមិត្តភាពពុំមានទោសទេ។ ល្បែងដែលមានទោស ដូចជាល្បែងបៀអាប៉ោងល្បែងកាស៊ីណូជាដើម។ ល្បែងស៊ីសងមានទោស៦យ៉ាង៖

១. **កាលឈ្នះរមែងបង្កឲ្យកើតពៀរ** សេចក្តីថា បើអ្នកលេងបានទទួលជ័យជំនះមួយគ្រា រមែងមានពៀរជាមួយអ្នកចាញ់ ដោយអ្នកចាញ់មិនសប្បាយចិត្ត អាចរករឿងជាមួយអ្នកឈ្នះ។

២. **កាលចាញ់រមែងសោកស្តាយទ្រព្យ** គឺអ្នកចាញ់តែងដេកកើតទុក្ខ។

៣. **ទ្រព្យសម្បត្តិតែងវិនាស** គេកម្រឃើញអ្នកលេងល្បែងមានកំណើតមានទ្រព្យសម្បត្តិដោយការលេងល្បែងឡើយ បើនៅប្រទេសកម្ពុជាឮតែលក់គោលក់ក្របីលក់ផ្ទះសម្បែង ឈ្លោះទាស់ទែងប្តីប្រពន្ធដោយសារការអស់ទ្រព្យគឺ

ខាតទាំងចុងខាតទាំងដើម មានអ្នកចាញ់ខ្លះធ្វើជាចោរលួចប្លន់ មានអ្នករាជការខ្លះប្រព្រឹត្តអំពើពុករលួយ។

៤. **មិនមានអ្នកណាមួយជឿពាក្យ** គឺគេពុំជឿពាក្យសំដីអ្នកលេងល្បែងឡើយ ព្រោះគេខ្លាចបោកគេយកប្រាក់ទៅលេងល្បែង។

៥. **ជាទីមើលងាយនៃមិត្តអាត្មា** មិត្តសំឡាញ់មិនឲ្យតម្លៃ និងពោលរិះគន់និងមិនជឿទុកចិត្តមិត្តដែលលេងល្បែងឡើយ។

៦. **មិនមានសប្បុរសចងជាមិត្រ** ធម្មតាលោកអ្នកសប្បុរសពុំសេពគប់មនុស្សអាក្រក់មានមនុស្សលេងល្បែងជាដើមឡើយ។

ទោសទាំង៦នេះ ឃើញក្នុងបច្ចុប្បន្នទាន់ភ្នែក។ ពាក្យខ្មែរក៏ពោលថា លេងល្បែងតែងវិនាស។ នៅក្នុង**បរាភវសូត្រ** គម្ពីររបស់ពុទ្ធសាសនានិយាយអំពីល្បែងបីប្រការនាំឲ្យវិនាស លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា ឆ្កួតមួយនឹងល្បែង អំពើពាលា ឆ្កួតនេះហៅមហា ឆ្កួតក្រែកន្លង។ ព្រះពុទ្ធជាម្ចាស់បង្រៀនឲ្យមនុស្សខំប្រឹងប្រែងធ្វើការងារដ៏ប្រពៃ (**សម្មាអាជីវោ**) ការងារដែលប្រកបដោយធម៌សុចរិត ជៀសវាងការ

ងារទុច្ចរិតនិងការងាររបៀបផ្សងព្រេងមានការលេងល្បែងជាដើម។

នៅភ្នំពេញ ប្រទេសកម្ពុជា នៅថ្ងៃ២៥កុម្ភៈ២០០៩ រាជរដ្ឋាភិបាលខ្មែរបានប្រកាសបិទអាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិកនិងមេកានិកគ្រប់ប្រភេទ(ស្លុតម៉ាស៊ីន) និងល្បែងភ្នាល់កីឡាគ្រប់ប្រភេទ(Cambosix) ព្រមទាំងល្បែងស៊ីសងដទៃទៀត ឆ្នោត កន្ទុយលេខ បៀ អាប៉ោង ជល់មាន់ ល្បែងភ្នាល់បាល់ ក៏ត្រូវបិទទាំងអស់ឲ្យតែល្បែងស៊ីសង។ ការប្រកាសបិទនេះមានការអបអរសាទរគ្រប់មជ្ឈដ្ឋាន ជាពិសេសស្របតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស។ ល្បែងស៊ីសងទាំងនេះ ធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ដល់សីលធម៌រស់នៅរបស់ប្រជាពលរដ្ឋទូទាំងប្រទេស បង្កឲ្យមានអំពើហឹង្សាក្នុងគ្រួសារ និងធ្វើឲ្យមានអសន្តិសុខ ប៉ះពាល់ដល់សុវត្ថិភាពនិងស្ថេរភាពសណ្តាប់ធ្នាប់ក្នុងសង្គម។ ការបិទនេះ ក៏ស្របតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលព្រះអង្គហាមកុំឲ្យពុទ្ធបរិស័ទរបស់ព្រះអង្គប្រព្រឹត្ត ព្រោះល្បែងតែងវិនាស។

គួររំលឹកឡើងវិញ ប្រទេសកម្ពុជាមានធ្វើវិនីយោគទុនបើកបនល្បែងកាស៊ីណូជាច្រើនកន្លែងនៅទីក្រុងភ្នំពេញនិងនៅតាម

ព្រំដែនខ្មែរថៃនិងនៅតាមព្រំដែនខ្មែរវៀតណាម។ តាមគម្រោងរបស់រាជរដ្ឋាភិបាលខ្មែរថា កាស៊ីណូទាំងនោះអនុញ្ញាតឲ្យបង្កើតសំរាប់តែជនបរទេសលេងទេ ប៉ុន្តែគេសង្កេតឃើញថាខ្មែរក៏មានទៅលេងជាមួយជនបរទេសដែរ។ គួរឲ្យស្តាយមួយទៀត មានអាគារកាស៊ីណូមួយនៅទីក្រុងភ្នំពេញខ្ពស់ស្កឹមស្កៃជាងព្រះបរមរាជវាំងដែលជាស្ថាប័នកំពូលរបស់ខ្មែរទៅទៀត។ ក្រៅពីនោះទៀត តាមសារពត៌មានរស្មីកម្ពុជាដែលជាសារពត៌មានដ៏ធំ បានផ្សាយនៅថ្ងៃ៩សីហា២០០៤និយាយថា ប្រទេសកម្ពុជាជាពិភពល្បែងឆ្នោតធំជាងគេនៅលើពិភពលោក។ មានក្រុមហ៊ុនបរទេសលេងឆ្នោត៦ ចេញឆ្នោតទាំងយប់ទាំងថ្ងៃមានលេខ២ខ្ទង់លេខ៣ខ្ទង់ក្នុង១ថ្ងៃចេញ១៣ដង។ ក្រុមហ៊ុនទាំង៦នោះបានចំណេញកើបយកប្រាក់ពីប្រជាពលរដ្ឋខ្មែរ ក្នុង១ឆ្នាំបានជាច្រើនលានដុល្លាសហរដ្ឋអាមេរិក។ អាជ្ញាប័ណ្ណអនុញ្ញាតច្បាប់ឲ្យក្រុមហ៊ុនបរទេសទាំង៦បើកលេងឆ្នោតនេះ គឺចេញពីរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនិងខុទ្ទកាល័យនាយករដ្ឋមន្ត្រី។ បើពិចារណាឃើញទោសនៃការលេងល្បែងតាំងពីមុនអនុញ្ញាតអាជ្ញាប័ណ្ណ ប្រហែលមិនពិបាកបិទទេ។

ដោយប្រទេសកម្ពុជាជាប្រទេសគោរពព្រះពុទ្ធសាសនា ហើយពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធមានខ្លឹមសារ សំរាប់អប់រំឲ្យមនុស្សមានតម្លៃថ្លៃថ្នូរ មានឲ្យវៀរចាកអំពើអបាយមុខ ដែលជាប្រធាននៃសេចក្ដីវិនាសទាំងបី គឺល្បែងស្រី ល្បែងស្រា និងល្បែងស៊ីសងជាដើម គួរអ្នកទទួលខុសត្រូវវាសនាជាតិខ្មែរពិចារណាមើលតើគួរបិទល្បែងណាទៀត ហើយសម្លឹងមើលការវិនិយោគទុនផ្សេងពីនេះវិញ ដើម្បីអភិវឌ្ឍន៍ប្រទេសកម្ពុជាឲ្យបានចំរើនលូតលាស់បន្តទៅទៀត។

# ១២- មនុស្សឆ្កួត៨ពួក

មនុស្សឆ្កួត៨ពួក ដែលមាននិយាយក្នុងសុត្តន្តបិដក ផ្នែកពួកកងធម៌នោះគឺ៖

**១. កាមុម្មត្តកោ** ឆ្កួតព្រោះកាម ពាក្យថាកាមនេះ ប្រែថា ចិត្តស្ទុះទៅ គឺស្ទុះទៅកាន់រូបសម្លេងក្លិនរសនិងសម្ផស្ស ចិត្តជាប់នឹងវត្ថុកាមទាំង៥នេះ។ ហេតុអ្វីបានជាលោកពោលថា ទៅជាឆ្កួត បានជាទៅជាឆ្កួតព្រោះអ្នកដែលជាប់ចិត្តខ្លាំងឬងប់ខ្លាំង នាំឲ្យវង្វេង លែងដឹងខុសត្រូវបុណ្យបាបគុណទោសអ្វីទាំងអស់ ដូចជាការជាប់ចិត្តក្នុងរូប សូម្បីប្រពន្ធកូនគេក៏ហ៊ានរំលោភដែរ។ ពាក្យខ្មែរក៏បានពោលថា លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា ឆ្កួតមួយនិងល្បែង អំពើពាលា ឆ្កួតនេះហៅមហាឆ្កួតក្រៃកន្លង។ ពាក្យថាកាមមានរូបជាដើមនេះ ពុំមែនសំដៅយកតែភេទប្រុសភេទស្រីទេ គឺសំដៅយកអ្វីទាំងអស់ ឲ្យតែចិត្តជាប់ហៅថាកាមទាំងអស់ គឺចិត្តជាប់ហៅថា **កិលេសកាម** វត្ថុដែលចិត្តជាប់ហៅថា **វត្ថុកាម**។ កាមគុណទាំង៥នេះ ធ្វើឲ្យអ្នកធំអ្នកតូចវង្វេងខ្លាំងណាស់ រហូតដល់ធ្វើឲ្យខូចប្រយោជន៍

ដល់សង្គមទៀត។ ការជួញដូរមនុស្ស ការរំលោភផ្លូវភេទ សុទ្ធតែកើតឡើងពីកាមគុណនេះឯង។

២. **ទោសុម្មត្តកោ** ឆ្កួតព្រោះសេចក្តីក្រោធ ធម្មតាអ្នកក្រោធខឹងតែងភ្លេចខ្លួនវង្វេងមិនដឹងខុសត្រូវ ប្រព្រឹត្តធ្វើអំពើតាមកំហឹងរបស់ខ្លួន ប៉ះពាល់ដល់សិទ្ធិអ្នកដទៃនិងរំលោភច្បាប់។ ការប្រព្រឹត្តឧក្រិដ្ឋកម្ម មានការធ្វើឃាតអ្នកដទៃជាដើម កើតឡើងពីសេចក្តីក្រោធខឹងនេះឯង បានជាលោកពោលថា ឆ្កួតព្រោះសេចក្តីក្រោធ។

៣. **ទិដ្ឋុម្មត្តកោ** ឆ្កួតព្រោះយល់ខុស ការយល់ខុសនេះជាឫសគល់នៃអកុសលទាំងពួង ដូចជាយល់ថាធ្វើបាបមិនបានបាបជាដើម។ កាលបើយល់ដូច្នេះ មនុស្សនឹងធ្វើអំពើបាបដោយគ្មានញញើតដៃ ព្រោះយល់ថាអំពើបាបគ្មានឲ្យផលជាទុក្ខ បានជាចាត់ថាជាឆ្កួត។

៤. **មោហុម្មត្តកោ** ឆ្កួតព្រោះសេចក្តីវង្វេង **មោហៈ**នេះកើតខ្លួនឯងផងទៅជំនួយគេផង។ កើតខ្លួនឯង គឺចិត្តសង្ស័យនិងចិត្តរាយមាយ។ ជំនួយគេគឺ បើលោភៈនិងទោសៈកើតឡើងដូចជាលួចទ្រព្យសម្បត្តិអ្នកដទៃ លួចទ្រព្យសម្បត្តិជាតិ លួចធ្វើឃាតអ្នកដទៃជាដើម **មោហៈ**នេះទៅជំនួយបិទបាំងមិនឲ្យគិត

ឃើញថា អំពើនេះខុសនាំឲ្យមានទោសឡើយ បានជាចាត់ជាឆ្កួត ព្រោះអ្នកឆ្កួតវង្វេងស្មារតីមិនដឹងខុសត្រូវឡើយ។

**៥. យក្ខុម្មត្តកោ** ឆ្កួតព្រោះយក្ខចូលបៀតបៀន។ យក្ខក្នុងទីនេះ បានដល់ពួកអសុរកាយខ្មោចព្រាយបិសាចមកយាយីបៀតបៀនមនុស្ស ធ្វើឲ្យមនុស្សវង្វេងស្មារតី។ ពាក្យសំដីកាយវិការរបស់មនុស្សនោះ មានលក្ខណៈរវើរវាយ គឺជាអាការៈដែលបណ្ដាលឡើងដោយសារពួកអសុរកាយនោះ របៀបមនុស្សឆ្កួត។

**៦. បិត្តុម្មត្តកោ** ឆ្កួតព្រោះប្រមាត់កំរើក ប្រមាត់ជាអង្គធាតុមួយមានមុខងារបញ្ចេញទឹករបស់វា បើទឹកប្រមាត់នេះកំរើក ធ្វើឲ្យមនុស្សស្រវាំងភ្នែកវិលមុខ ភ្លេចមុខភ្លេចក្រោយ។ ពាក្យនេះអាចនិយាយរហូតដល់ខូចសរសៃប្រសាទ ខូចខួរក្បាល ក៏នាំឲ្យមនុស្សវង្វេងស្មារតីទៅជាឆ្កួតដែរ។

**៧. សុរុម្មត្តកោ** ឆ្កួតព្រោះសុរា សុរាជាភេសជ្ជៈមួយប្រភេទមានធាតុក្ដៅ ដែលធ្វើឲ្យអ្នកផឹកច្រើនស្រវឹងវង្វេងស្មារតី និយាយច្រើនគ្មានដឹងខុសត្រូវ ព្រោះក្ដៅខ្លាំងដល់សរសៃវិញ្ញាណទៅជាឆ្កួតវង្វេង។

**៨. ព្យសនុម្មត្តកោ** ឆ្កួតព្រោះជួបប្រទះនឹងសេចក្ដីវិនាសទៅជាក្រឡកចិត្តឬខូចចិត្ត។ បានដល់មនុស្សដែលមានវិបត្តិ

ធ្ងន់ៗដូចជាវិនាសទ្រព្យសម្បត្តិ ព្រាត់ប្រាស ស្លាប់បាត់បង់សមាជិកគ្រួសារជាទីគោរពនិងជាទីស្រឡាញ់ ក៏សោកស្តាយខ្លាំងទៅជាឆ្កួតវង្វេងស្មារតី។

## ការបំបាត់ឆ្កួតទាំង៨ពួកនេះ

ដើម្បីបន្ថយឬរំលត់នូវការត្រេកអរក្នុងកាមគុណ ត្រូវពិចារណានូវភាពមិនស្អាតនៃរូបកាយ។ ការរំលត់នូវសេចក្តីក្រោធគប្បីផ្សាយមេត្តាករុណា បង្កើតការរាប់អាននិងការអាណិតអាសូរ។ ដើម្បីកុំឲ្យមានការយល់ខុស ត្រូវចូលទៅសេពគប់លោកសប្បុរសហើយស្តាប់ធម៌ដែលលោកសំដែងដោយសេចក្តីគោរព។ ដើម្បីរំលត់នូវមោហៈ ត្រូវឧស្សាហ៍ស្តាប់និងពិចារណាធម៌ជាពិសេសពិចារណានូវទោសរបស់អកុសល។ ដើម្បីកុំឲ្យខ្មោចបិសាចបៀតបៀន ត្រូវពិចារណាកម្មផលនិងផ្សាយមេត្តាចិត្ត។ ដើម្បីជៀសវាងជម្ងឺប្រមាត់និងខូចសរសៃប្រសាទ ត្រូវមានអនាម័យរក្សាទឹកចិត្តឲ្យល្អ បើអង្គធាតុនេះឈឺ ត្រូវព្យាបាលនៅមន្ទីរពេទ្យ។ ដើម្បីជៀសវាងឆ្កួតព្រោះស្រា ត្រូវឈប់ផឹកស្រា ត្រូវពិចារណាទោសពីការផឹកស្រា បើមានជម្ងឺត្រូវឲ្យពេទ្យព្យាបាល។ ឆ្កួតចិត្តព្រោះមានវិបត្តិធ្ងន់ ត្រូវពិចារណាកម្មផល ពិចារណានូវភាពពុំស្ថិតស្ថេរនៃមនុស្សសត្វនិងវត្ថុទាំងឡាយ។

# ១៣- ការឆ្កួតនឹងស្រី

នៅក្នុងព្រះពុទ្ធសាសនាមានសំដែងអំពីការឆ្កួតនឹងស្រីឬល្បែងស្រីនេះជាច្រើនកន្លែង ជាពិសេសនៅក្នុងសូត្រមួយហៅថា **បរាភវសូត្រ** ដែលពុទ្ធបរិស័ទខ្មែរតែងសូត្រនៅក្នុងឱកាសបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌ។ ការឆ្កួតនឹងស្រីបាលីថា **ឥត្ថីធុត្តោ** ជាល្បែងនាំឲ្យវិនាស (បរាភវតោមុខំ)។ ល្បែងស្រីក្នុងទីនេះ សំដៅយកការមានភរិយាហើយបែរជាទៅរកស្រីដទៃទៀតពុំសន្តោសក្នុងកាមគុណ គឺការល្មោភក្នុងកាមគុណរហូតហ៊ានរំលោភកូនប្រពន្ធអ្នកដទៃថែមទៀត។ ដូចមានក្នុងសិក្ខាបទទីបីនៃសីល៥ គឺ**កាមេសុ មិច្ឆាចារា វេរមណី** គឺឲ្យវៀរចាកការប្រព្រឹត្តខុសក្នុងកាម គឺវៀរចាកការលួចប្រពន្ធកូនប្តីអ្នកដទៃនេះឯង។ ទោះបីទៅប្រព្រឹត្តក្នុងបនស្រីពេស្យា ក៏មានទោសដូចគ្នា គឺអាចកើតរោគ អស់ប្រាក់កាស បង្កើតជម្លោះក្នុងគ្រួសារ ខូចកេរ្តិ៍ឈ្មោះខាតការងារជាដើម។ ការបង្កើតជម្លោះក្នុងគ្រួសារ បើនិយាយសង្គមគ្រួសារខ្មែរកាលពីជំនាន់ដើមប្តីកម្រមានប្រពន្ធចុងណាស់ គឺច្រើនមានមួយនឹងមួយ។ ប៉ុន្តែបច្ចុប្បន្ននេះ មានលក្ខណៈប្លែកពីជំនាន់ដើមខ្លះ គឺមានស្វាមីខ្លះ

ទៅរកស្រីខាងក្រៅរហូតកើតរោគអេដ៏មកចម្លងដល់ប្រពន្ធកូនទៀតផង។ កាលបើបុរសមានប្រពន្ធចុង នាំឲ្យមានជម្លោះក្នុងគ្រួសារអំពីប្រពន្ធចុងនិងប្រពន្ធដើម រហូតមានជះទឹកអាស៊ីដដាក់គ្នាជាដើម។ បើអ្នករដ្ឋការ អាចប្រព្រឹត្តអំពើពុករលួយដើម្បីរកប្រាក់មកចិញ្ចឹមប្រពន្ធចុង។ កាលពីដើម ជនជាតិខ្មែរមិនដែលស្គាល់ហើយមិនដែលកើតរោគអេដ៏ឬស៊ីដានេះទេ ឥឡូវជម្ងឺនេះបានឆ្លងមកដល់ប្រទេសកម្ពុជាដោយសារល្បែងស្រីនេះឯង។ រោគអេដ៏នេះបានឆ្លងមកដល់យុវជនខ្មែរខ្លះ ដោយសារតែមានបនស្រីពាសពេញប្រទេស។ មិនតែប៉ុណ្ណោះ មានការបញ្ឆោតឬចាប់ក្មេងស្រីយកទៅលក់ឲ្យផ្ទះបននិងលក់ចេញទៅក្រៅប្រទេស។ គេសង្កេតឃើញថា អ្នកដែលចាប់ស្ត្រីរំលោភស្រី បញ្ឆោតស្ត្រីឬទិញស្ត្រីនោះ ភាគច្រើនកើតចេញមកពីអ្នកមានដុល្លាច្រើន ពីអ្នកមានអំណាចនិងពួកទេសចរបរទេសផង។ អំពើអាក្រក់ទាំងអស់នេះ បង្កឲ្យមានសេចក្តីទុក្ខដល់ប្រជាពលរដ្ឋតូចតាច ហើយនាំឲ្យខូចទំនៀមទម្លាប់ដ៏ល្អរបស់ខ្មែរ។

ល្បែងស្រីដែលជាអំពើអបាយមុខដែលព្រះពុទ្ធហាមនេះកើតឡើងយ៉ាងខ្លាំងនៅប្រទេសកម្ពុជា ដោយសារតែច្បាប់និងការអនុវត្តច្បាប់នៅប្រទេសកម្ពុជាពុំបានតឹងរ៉ឹង តុលាការពុក

រលួយហើយអ្នកប្រព្រឹត្តអាក្រក់ចេះតែរួចចាកទោសដោយអំពើពុករលួយរបស់តុលាការ ឬរួចចាកទោសដោយការសម្រុះសម្រួលដោយឲ្យប្រាក់បន្តិចបន្តួចដល់អ្នករងគ្រោះ។ ជួនកាលម្តាយឪពុកក្រីក្រដែលកូនស្រីរបស់ខ្លួនត្រូវគេរំលោភ មិនហ៊ានទៅប្តឹងតុលាការ ព្រោះខ្លាចអ្នករំលោភនោះព្យាបាទនៅថ្ងៃក្រោយ ឬមិនហ៊ានទៅប្រាប់អាជ្ញាធរ ព្រោះមានការខ្មាសអៀនដែលជាហេតុនាំឲ្យជនឧក្រិដ្ឋ ចេះតែហ៊ានប្រព្រឹត្តអំពើនេះជាបន្តទៀត។ អំពើរំលោភស្ត្រីមួយទៀត កើតឡើងដោយសារទស្សនាវដ្តីនិងវីដេអូអាសអាភាសចូលមកប្រទេសកម្ពុជាដោយគ្មានការត្រួតពិនិត្យពីរដ្ឋឲ្យបានម៉ឺងម៉ាត់។ ជីវភាពក្រីក្ររបស់ប្រជាពលរដ្ឋ ខ្វះការអប់រំខាងសីលធម៌ និងភាពទន់ខ្សោយនៃចំណេះចេះដឹង ព្រមទាំងខ្វះពត៌មាន នាំឲ្យកុមារីខ្មែរឆាប់ចាញ់បោកជនទុច្ចរិតណាស់។ កុមារីខ្មែរត្រូវទទួលរងគ្រោះមានលក្ខណៈច្រើនសណ្ឋាន។

## ល្បិចបោកបញ្ឆោតរបស់ចិនតៃវ៉ាន់

ចិនតៃវ៉ាន់ដែលគេដឹងថា ច្រើនជាអ្នកមានហើយល្មោភខាងកាមគុណ បានប្រើល្បិចបោកបញ្ឆោតកុមារីក្មេងៗនៅប្រទេសក្រីក្រដូចប្រទេសកម្ពុជាជាដើម ដែលជាប្រទេសក្រីក្រផង

ហើយច្បាប់ទម្លាប់ធូរផង បានបោកបញ្ឆោតមាតាបិតានៃកុមារីខ្មែរ ក្រោមរូបភាពសុំកូនស្រីរៀបការយកធ្វើជាប្រពន្ធ។ ប៉ុន្តែបន្ទាប់ពីរៀបការបញ្ឆោតរួចមក គេនាំទៅប្រទេសគេប្រព្រឹត្តកាមគុណអស់ចិត្តហើយ គេលក់ឲ្យផ្ទះស្រីបនជាបន្តទៅទៀត។ មានកុមារីខ្មែរខ្លះ គេលក់ឲ្យទៅធ្វើខ្ញុំបំរើគេដោយដាច់ថ្លៃ ត្រូវគេបង្ខំឲ្យធ្វើការមានរហូតដល់វាយដំទៀតផង។ មានកុមារីខ្មែរតិចណាស់ ដែលគេយកទៅធ្វើជាប្រពន្ធឬធ្វើជាប្រពន្ធចុងពិតប្រាកដ ហើយការយកទៅធ្វើជាប្រពន្ធនោះ ពុំប្រាកដយករហូតឬយកតែមួយដំណើររទេ។ មិនត្រឹមតែចិនតៃវ៉ាន់ទេ ជនជាតិដទៃទៀត ដូចជាជនជាតិជប៉ុនជាដើម ក៏ប្រព្រឹត្តដូចគ្នានេះដែរ តែមានចំនួនតិចជាងចិនតៃវ៉ាន់។ តាមពត៌មានថា ប្រុសចិនតៃវ៉ាន់ដែលយកស្ត្រីខ្មែរ ក្រោមរូបភាពការលួចលាក់ ជាប្រុសចាស់ខ្លះពិការ ខ្លះពាលាអាវ៉ាសែ មិនចេះអក្សរ បាតផ្សារ។

មានក្រុមហ៊ុនមួយបានអនុញ្ញាតច្បាប់ពីរដ្ឋាភិបាលខ្មែរ បានរកការឲ្យកុមារីខ្មែរធ្វើនៅប្រទេសម៉ាឡេស៊ីដែលជាប្រទេសភាគច្រើនកាន់សាសនាឥស្លាម។ តាមដំណឹងតាមស្ត្រីខ្មែរដែលរត់ពីប្រទេសម៉ាឡេស៊ី ដែលត្រូវគេធ្វើបាបបានឲ្យការណ៍ថា រូបនាងបានត្រូវគេឲ្យទៅធ្វើការបំរើគេក្នុងគ្រួសារមួយ បាន

ត្រូវគេបង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃស្ទើរគ្មានពេលសម្រាក ហើយមានពេលខ្លះ បុរសជាមេគ្រួសារបង្ខំរូបនាងឲ្យបំរើគេក្នុងផ្លូវភេទផង។ នាងបានធ្វើអនុសាសន៍ថា សូមបងប្អូនស្ត្រីខ្មែរកុំចាញ់បោកឲ្យក្រុមហ៊ុននោះនាំយកទៅធ្វើការនៅម៉ាឡេស៊ីឲ្យសោះ ព្រោះរូបនាងមានការពិសោធន៍ហើយមានការពិបាកណាស់ គឺរូបនាងដូចគេយកទៅលក់ដោយដាច់ថ្លៃ គឺគ្មានការគោរពលក្ខខណ្ឌការងារដូចក្រុមហ៊ុននៅភ្នំពេញបានសន្យាឡើយ។ ពេលគេធ្វើបាប ស្ថានទូតខ្មែរប្រចាំនៅប្រទេសម៉ាឡេស៊ីគ្មានបានធ្វើអន្តរាគមន៍ជួយរំដោះទុក្ខទេ ព្រោះមានពេលខ្លះនាងត្រូវម្ចាស់ផ្ទះវាយធ្វើបាបផង។

ដោយភាពក្រីក្រ ប្រជាពលរដ្ឋខ្មែរបានបង្ខំចិត្តទៅរកស៊ីនៅប្រទេសថៃ ត្រូវថៃធ្វើបាប ពេលធ្វើការមានថៅកែខ្លះមិនឲ្យប្រាក់ឈ្នួលឬឲ្យហើយត្រូវជំរិតយកវិញដោយចោទថា មកប្រទេសគេខុសច្បាប់។ ប្រជាពលរដ្ឋខ្មែរខ្លះបានប្រាក់ខ្លះធ្វើដំណើរត្រឡប់មកមាតុប្រទេសវិញ ត្រូវឆ្មាំខ្មែរយាមព្រំដែនជំរិតយកអស់ទៀត។ ប្រជាពលរដ្ឋខ្មែរខ្លះបានត្រូវតម្រួតថៃបាញ់ត្រូវរបួសខ្លះ ស្លាប់ខ្លះ តាមផ្លូវ។ កុមារីនិងនារីខ្មែរខ្លះ បានត្រូវថៃរំលោភផ្លូវភេទថែមទៀត។

កុមារីខ្មែរខ្លះបានត្រូវមេខ្យល់លួងលោមថារកការឲ្យធ្វើ តែផ្ទុយទៅវិញបាននាំមកលក់ឲ្យស្រីបននៅក្នុងប្រទេស មានខ្លះលក់ទៅប្រទេសក្រៅដូចជាលក់ទៅប្រទេសថៃ ប្រទេសម៉ាឡេស៊ី ប្រទេសចិនជាដើម។ កូនស្រីខ្មែរខ្លះ បានត្រូវបងប្អូនរបស់ខ្លួនដូចជាបងប្អូនជីដូនមួយឬម្ដាយមីង បញ្ឆោតយកទៅលក់ដែរ។ ពិសេសទៅទៀត កូនស្រីខ្មែរខ្លះបានត្រូវអ្នកធំអ្នកមានអំណាចឲ្យប្រាក់ម្ដាយឪពុកជារបៀបទិញដូរហើយយកមកប្រព្រឹត្តកាមគុណដោយគ្មានការអៀនខ្មាសជាអំពើអមនុស្សធម៌។ ក្រៅពីនោះ មានអ្នកទេសចរបរទេសខិលខូចដើររកកុមារីក្មេងៗដើម្បីរួមភេទដោយមានឈ្មួញទុច្ចរិតខ្មែរធ្វើសហការជួយរកផង។

អំពើអបាយមុខល្បែងស្រីនៅប្រទេសកម្ពុជានេះ មានគ្រោះថ្នាក់ដល់ប្រទេសធ្ងន់ណាស់ បើពុំកំចាត់ឲ្យទាន់ពេលវេលាទេ។ នៅប្រទេសដែលជឿនលឿនខាងអារ្យធម៌ គេមិនដែលឲ្យកើតមានស្រីបនពាសពេញប្រទេសដូចកម្ពុជាទេ សូម្បីក្នុងសណ្ឋាគារ គេពុំអនុញ្ញាតឲ្យយកស្រីលួចលាក់បែបណាមួយប្រព្រឹត្តកាមគុណក្នុងសណ្ឋាគារឡើយ។ បើមានហេតុនេះកើតឡើង

អ្នកធ្វើការក្នុងសណ្ឋាគារធ្វើសហការជាមួយអាជ្ញាធរ ទូរស័ព្ទទៅប៉ូលិសឲ្យមកឆែកឆ្លាម។

មាតាបិតាឬអាណាព្យាបាលនៃបុត្រីខ្មែរទាំងឡាយត្រូវពិចារណាឲ្យម៉ត់ចត់ កុំផ្សងព្រេងឲ្យបុត្រីរបស់ខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយបុរសចិនតៃវ៉ាន់ឬជនជាតិបរទេសដទៃទៀតដែលពុំបានដឹងល្បិចកិច្ចកលរបស់គេ ពាក្យខ្មែរពោលថា «ធ្វើស្រែឲ្យមើលស្មៅទុកដាក់កូនចៅឲ្យមើលផៅសន្តាន» កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្កមណ៍ កុំទុកចិត្តអភិប្រាយ។ ភស្តុតាងជាច្រើនបានឲ្យដឹងថា បុត្រីខ្មែរជាច្រើនបន្ទាប់ពីរៀបអាពាហ៍ហើយ គេយកទៅលក់បន្តទៅទៀតឲ្យធ្វើជាស្រីពេស្យា។ ការសម្រេចចិត្តខុស ទុកដូចជាសម្លាប់កូនរបស់ខ្លួន។ មួយទៀត អាជ្ញាធរខ្មែរគួរពិចារណាមើល ការអនុញ្ញាតច្បាប់ឲ្យជនបរទេសរៀបអាពាហ៍ពិពាហ៍ជាមួយខ្មែរ ព្រោះការអនុញ្ញាតពីមុនមានគ្រោះថ្នាក់ដល់ស្រ្តីខ្មែរ។

អាជ្ញាធរខ្មែរ គួរពិនិត្យមើលក្រុមហ៊ុនមួយនៅភ្នំពេញដែលបង្កើតមុខរបរទាក់ទាញស្រ្តីខ្មែរឲ្យទៅបំរើក្នុងផ្ទះនៅប្រទេសម៉ាឡេស៊ី ដែលត្រូវម្ចាស់ផ្ទះធ្វើបាបដូចជាទាសករដាច់ថ្លៃ។ ស្ថានទូតខ្មែរប្រចាំប្រទេសម៉ាឡេស៊ីមិនត្រូវព្រងើយកន្តើយទេ ត្រូវតែ

ជួយដោះស្រាយឲ្យកូនស្រីទាំងនោះរួចជាអ្នកជា ហើយវិលត្រឡប់មកស្រុកកំណើតវិញ ព្រោះការទៅបំរើគេដាច់ថ្លៃដូច្នេះ នាំឲ្យខូចកិត្តិយកប្រទេសកម្ពុជា ដែលធ្លាប់មានអារ្យធម៌ខ្ពង់ខ្ពស់សម័យបុរាណ។

ប្រជាពលរដ្ឋខ្មែរដោយភាពក្រីក្របានទៅស៊ីឈ្នួលគេនៅថៃ ត្រូវថៃធ្វើបាបប្រមាថមើលងាយចាប់រំលោភនារីខ្មែរ មានរហូតដល់បាញ់សម្លាប់។ ត្រង់នេះ អាជ្ញាធរខ្មែរត្រូវតែប្រញាប់ប្រញាល់ដោះស្រាយជាមួយអាជ្ញាធរថៃដែលជាប្រទេសកាន់ព្រះពុទ្ធសាសនា តែប្រព្រឹត្តអំពើអមនុស្សធម៌មកលើប្រជាពលរដ្ឋខ្មែរស្លូតត្រង់បែបនេះ។

អាជ្ញាធរខ្មែរ គប្បីតាមដានឲ្យម៉ឺងម៉ាត់ចំពោះមេបនដែលទាក់ទាញស្ត្រីខ្មែរឲ្យបំរើផ្លូវភេទនៅក្នុងផ្ទះបនក្នុងប្រទេសនិងលក់ទៅបរទេស យកមកផ្ដន្ទាទោសតាមច្បាប់។ ការលក់ការជួញដូរមនុស្សនេះ មិនថាតែច្បាប់ផ្លូវអាណាចក្រទេ ដែលហាមឃាត់ ព្រះពុទ្ធសាសនាបានហាមឃាត់ជាដាច់ខាត ដោយបាលីថា **សត្តវណិជ្ជា** ប្រែថា កុំជួញដូរមនុស្សគឺកុំចាប់មនុស្សលក់ ព្រោះមនុស្សមានជាតិដូចគ្នា កុំបន្ថោកបន្ទាបតម្លៃរបស់មនុស្ស។ អ្នកសង្កេតការណ៍ មានការសង្ស័យថា ការជួញដូរស្ត្រីខ្មែរមាន

បង្អែកយ៉ាងមាំពីអ្នកមានអំណាច បានជាការជួញដូរនេះប្រព្រឹត្ត ទៅយ៉ាងងាយៗបែបនេះ។ បើការសង្ស័យនេះ ជាការពិត ត្រូវ អាជ្ញាធរថ្នាក់លើ តាមដានចាប់អ្នកនោះ មកកាត់ទោស។

វិធានការក្រៅពីនេះ ត្រូវទប់ស្កាត់វប្បធម៌អាសអាភាសដូច ជាវីដេអូ ព្រឹត្តិប័ត្រកុំឲ្យចូលមកប្រទេសកម្ពុជា។ អ្នកនិពន្ធខ្មែរ គ្រប់ប្រភេទ គឺនិពន្ធជារឿងកុនក្តីជាបទចម្រៀងក្តី ត្រូវនិពន្ធ ណែនាំទៅរកសីលធម៌ការគោរពសិទ្ធិគ្នា ការស្រឡាញ់ទឹកដី មាតុប្រទេសរបស់ខ្លួន ជៀសវាងរឿងអាសអាភាសនិងអំពើ ហឹង្សា។ ជាពិសេស រដ្ឋាភិបាលខ្មែរត្រូវតែបិទផ្ទះបនស្រីបេស្យា ទាំងអស់ក្នុងប្រទេសកម្ពុជាទាំងមូល ព្រោះការមានផ្ទះបននាំ ឲ្យបុរសទៅផ្ទះបនប្រព្រឹត្តកាមគុណ ជាប្រភពនាំឲ្យកើតរោគ អេដ៏ ជាប្រភពនាំឲ្យកើតការវិវាទគ្នា ជាប្រភពមួយផ្នែកនៃអំពើ ពុករលួយនិងនាំឲ្យយុវជនខ្មែរ ដែលជាអនាគតរបស់ប្រទេស ទៅប្រព្រឹត្ត នាំឲ្យខូចសុខភាព និងខូចការសិក្សា។

ឈឈឈឈឈ

# ១៤- ប្រយ័ត្នទេសចររួមភេទ

តាមពត៌មានជាបន្តបន្ទាប់ពីប្រទេសកម្ពុជាថា មានក្រុមទេសចរបរទេសខ្លះ បានដើរទិញស្រីខ្មែរវ័យក្មេងនៅតាមទីក្រុង និងនៅតាមស្រុកស្រែចំការខ្មែរយកមករួមរភេទ ដោយមានសហការជាមួយខ្មែរខ្លះនៅក្នុងស្រុកជួយផង ដោយគេគិតតែពីដុល្លា គ្មានការអាណិតអាសូរដល់ជនរួមជាតិរបស់ខ្លួន ដែលក្រីក្រនិងទន់ខ្សោយប្រាជ្ញាស្មារតីសោះឡើយ។ មានប្រើវិធីមួយទៀត គឺការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ដូចករណីជនបរទេសម្នាក់ បានរៀបអាពាហ៍ពិពាហ៍ជាមួយនារីខ្មែរមានវ័យក្មេងម្នាក់បានតែប៉ុន្មានខែទៅរៀបការជាមួយស្រីជំទង់ខ្មែរម្នាក់ទៀតអាយុ១៦ឆ្នាំ។ ដូច្នេះ គ្រាន់តែរយៈពេលប៉ុន្មានខែប៉ុណ្ណោះ ជនបរទេសនោះបានបង្ខូចអនាគតកូនស្រីខ្មែរអស់ពីរនាក់ គ្រាន់តែចំណាយពីរបីរយដុល្លាប៉ុណ្ណោះដោយយករូបភាពអាពាហ៍ពិពាហ៍បាំងមុខ ដោយម្តាយឪពុកយល់ច្រឡំថា គេយកកូនខ្លួនធ្វើជាប្រពន្ធពិតប្រាកដ។ វិធីបោកនេះបានជោគជ័យណាស់ បើយកប្រាក់ទិញត្រង់ៗជាអំពើខុសច្បាប់។ ករណីនេះ មានកើតឡើងនៅខេត្តសៀមរាប។

នៅខេត្តសៀមរាបជិតអង្គរវត្តមានជនជាតិបរទេសម្នាក់ឈ្មោះ Robert មានផ្ទះមួយផ្ទាល់ខ្លួនបានចិញ្ចឹមស្រីជំទង់ខ្មែរបីនាក់រួមទាំងស្រីខ្មែរម្នាក់ទៀតជាប្រពន្ធត្រូវជាប្អូននាក់។ ក្នុងបណ្តាស្រីខ្មែរ៣នាក់ដែលRobertចិញ្ចឹម ត្រូវRobertរំលោភផ្លូវភេទទាំងអស់។ ក្រោយមកRobertបានបោកស្រីជំទង់ខ្មែរម្នាក់ទៀតអាយុ៩ឆ្នាំយកមកចិញ្ចឹម ក៏ត្រូវRobertរំលោភទៀត។ ឥឡូវនេះ ប៉ូលិសខ្មែរសហការជាមួយអង្គការក្រៅរដ្ឋាភិបាលបានចាប់Robertដោយមានភ័ស្តុតាងអ្នករងគ្រោះ និងភ័ស្តុតាងវីដេអូដែលRobertបានថតខ្លួនឯងពេលរួមភេទ និងចាប់ស្រីមេអណ្តើកដែលហៅថាប្រពន្ធRobertនោះផង។ តុលាការខ្មែរនៅសៀមរាបបានកាត់ទោសRobertឲ្យជាប់គុក២០ឆ្នាំ។ Robert សុំឧទ្ធរណ៍ដើម្បីទុកឱកាសឲ្យខ្លួនយកប្រាក់ទៅសូកតុលាការក្រែងបានរួចខ្លួន។ ពត៌មានទាំងពីរបានដកស្រង់តាមពត៌មានវិទ្យុបារាំងអន្តរជាតិ។ គួររំលឹកឡើងវិញថា ចំនួនពីរឆ្នាំមុននេះជនជាតិជប៉ុនម្នាក់អាយុជាង៦០ឆ្នាំ បានរៀបការជាមួយស្រីខ្មែរនៅខេត្តសៀមរាបជាង៦០នាក់ គ្រាន់តែចំណាយប្រាក់មួយរយពីររយរហូត៥០០ដុល្លាប៉ុណ្ណោះ អាចបំពេញសេចក្តីសប្បាយរបស់ខ្លួនតាមផ្លូវកាមគុណបាន លើគំនរទុក្ខរបស់ស្រីខ្មែរ។ គួរ

ឲ្យស្តាយ ម្តាយឪពុកខ្មែរទៅទុកចិត្តជនបរទេសហ៊ានប្រគល់កូនស្រីរបស់ខ្លួនឲ្យជនបរទេស ក្រោមរូបភាពយកធ្វើជាកូនរហូតដល់វារំលោភដូចជាជនពាលRobertនេះ។ អ្នកទេសចរមួយភាគដើររកស្រីក្មេងៗដើម្បីរួមភេទ ដូច្នេះម្តាយឪពុកខ្មែរមិនគួរល្ងង់ជឿទុកចិត្តជនបរទេសប្រគល់កូនស្រីឲ្យគេ ដូចយកស្តុរប្រគល់ឲ្យស្រមោច។ នេះជាមេរៀនសំរាប់ម្តាយឪពុកខ្មែរដទៃទៀតកុំយកតម្រាប់តាម។

មានប្រុសជាតិតៃវ៉ាន់ជាច្រើននាក់បានរៀបការលួចលាក់ជាមួយស្ត្រីខ្មែរនៅតាមស្រុកស្រែចំការខ្មែរ ថាយកទៅធ្វើជាប្រពន្ធ ប៉ុន្តែក្រោយមកបានឮដំណឹងថាយកទៅឲ្យធ្វើជាស្រីពេស្យាដោយលក់ជាបន្តពីមួយទៅមួយ។ ស្ត្រីខ្មែរមួយភាគត្រូវគេធ្វើជាល្បិចរៀបការ ប៉ុន្តែគេយកទៅឲ្យធ្វើការក្នុងរោងចក្រដោយមេខ្យល់កេងប្រវញ្ចន៍ពីលើ ភាគតិចណាស់ដែលយកទៅធ្វើប្រពន្ធពិតប្រាកដ ហើយស្ត្រីខ្មែរដែលគេយកទៅធ្វើជាប្រពន្ធនោះ ត្រូវម្តាយក្មេកធ្វើបាបបំរើគេដាច់ថ្លៃ។ ប្រុសចិនតៃវ៉ាន់ដែលការស្រីខ្មែរលួចលាក់នោះ ជាប្រុសចាស់មានខ្លះពិការ ខ្លះល្ងង់ខ្លៅមិនចេះអក្សរ ខ្លះមានលក្ខណៈបាតផ្សារ។ ស្រីខ្មែរដែលនៅចិនតៃវ៉ាន់សព្វថ្ងៃមានចំនួន៥០០០នាក់ ភាគច្រើនមិនទាន់

មានច្បាប់រស់នៅចិនតែវ៉ាន់នៅឡើយ។ បើមានបញ្ហាអ្វី ស្ត្រីខ្មែរទាំងនោះមានការពិបាកណាស់ គ្មានអ្នកជួយដោះស្រាយ ព្រោះខ្មែរពុំមានស្ថានទូត។

សព្វថ្ងៃ ខ្មែរនៅមានភាពក្រីក្រ ហើយនៅទន់ខ្សោយបញ្ញាស្មារតីបានជាជនបរទេសប្រភេទនេះ ប្រមាថមើលងាយខ្មែរដែលធ្លាប់មានអារ្យធម៌ខ្ពង់ខ្ពស់ពីបូរាណ ទាញស្ត្រីខ្មែរឲ្យធ្លាក់មកធ្វើជាទាសករបំរើផ្លូវភេទយ៉ាងថោកទាបបំផុត។ មិនត្រឹមតែអ្នកទេសចរបរទេសទេដែលមើលងាយស្ត្រីខ្មែរ សូម្បីតែខ្មែរគ្នាឯងក៏មើលងាយស្រីខ្មែរដែរ គឺអ្នកមានអំណាចខ្មែរខ្លះយកប្រាក់ទៅទិញកូនស្រីពីម្ដាយឪពុកក្រីក្រខ្មែរយកមករួមភេទដែរ ក្រោមរូបភាពធ្វើជាស្រីកំណាន់ចិត្ត។ ស្រីខ្មែររងគ្រោះភាគច្រើនមិនត្រូវបានគេរកយុត្តិធម៌ឲ្យឡើយ ព្រោះតុលាការខ្មែរត្រូវគេចោទថាពុករលួយ អ្នកប្រព្រឹត្តអាក្រក់ចេះតែរួចខ្លួនពីសំណាញ់ច្បាប់។ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានព្រមានជាញឹកញាប់ដល់រាជរដ្ឋាភិបាលខ្មែរ ឲ្យខំប្រឹងប្រែងទប់ស្កាត់ការជួញដូរមនុស្សនិងទេសចររួមភេទឲ្យខ្លាំងបន្ថែមទៀត។

# សេចក្តីអំពាវនាវ

**១**. មាតាបិតាដែលមានកូនស្រី គប្បីប្រុងប្រយ័ត្នកុំចាញ់បោកអ្នកទេសចរបរទេសនិងជនជាតិខ្មែរណាដែលចង់យកកូនស្រីរបស់ខ្លួនទៅរួមភេទ ដោយវិធីបោកប្រាសក្រោមផ្លាករៀបការយកទៅធ្វើជាប្រពន្ធ ក្រោមផ្លាកយកទៅធ្វើជាកូនចិញ្ចឹមនិងក្រោមផ្លាកជួយរកការឲ្យធ្វើនិងវិធីបោកបញ្ឆោតផ្សេងៗទៀត។ សូម្បីម្តាយមីងឪពុកមាឬញាតិមិត្តផ្សេងៗទៀតក៏កុំជឿ ព្រោះមេអណ្តើកដែលជាធ្នាក់ គេរកអ្នកណាដែលមានភាពជិតដិតជាមួយម្តាយឪពុកកូនស្រីនោះ។ សូមម្តាយឪពុកដែលមានកូនស្រីកុំប្រថុយ កុំស្មាន កុំផ្សងព្រេង កុំជឿគ្រូទាយប្រគល់កូនស្រីឲ្យទៅគេដោយខ្វះការពិចារណា នាំឲ្យខូចអនាគតកូនស្រី ខូចកេរ្តិ៍ឈ្មោះគ្រួសារ និងខូចកិត្តិយកជាតិខ្មែរ។ ពាក្យបូរាណខ្មែរពោលថា កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្កមណ៍ កុំទុកចិត្តអភិប្រាយ។ កុំទុកចិត្តអភិប្រាយ គឺការនិយាយបញ្ចុះបញ្ចូលការនិយាយលួងលោមដូចនិយាយធានាថា បើឲ្យកូនស្រីទៅបំរើផ្ទះគេអ្នកមាន នោះនឹងបានប្រាក់ខែច្រើនជាដើម។ ពាក្យខ្មែរមួយឃ្លាទៀតពោលថា ធ្វើស្រែខុសមួយឆ្នាំត្រូវមួយឆ្នាំ យកប្តីប្រពន្ធមិនចំណាំខុសមួយជីវិត។ ក៏ដូចជាពាក្យថា ធ្វើស្រែឲ្យ

មើលស្មៅ ទុកដាក់កូនចៅឲ្យមើលផៅសន្តានជាដើម។ ពាក្យខ្មែរពោលថា សូវឲ្យខូចទ្រព្យសម្បត្តិមាសប្រាក់ កុំឲ្យខូចកិត្តិយស។ សូវឲ្យក្រទ្រព្យសម្បត្តិ កុំឲ្យខូចអនាគតកូន។ ខ្មែរជំនាន់ដើមទុកដាក់កូនចៅឲ្យមានគូស្រករច្រើនអ្នកនៅជិតខាងភូមិជាមួយគ្នា ព្រោះស្គាល់ចរិយាមារយាទគ្នាទៅវិញទៅមក។ សម័យនេះ មានការបោកប្រាស់ដោយប្រើល្បិចច្រើនណាស់ត្រូវតែប្រុងប្រយ័ត្ន។

២. សូមអាជ្ញាធរខ្មែរគ្រប់ជាន់ថ្នាក់ ជាពិសេសអាជ្ញាធរមូលដ្ឋាន ដូចជាចៅសង្កាត់មេភូមិជំទប់គ្រប់ភូមិស្រុកខេត្តរាជធានីទូទាំងប្រទេសកម្ពុជាទាំងមូល ធ្វើសហការគ្នាកំចាត់មេអណ្តើកខ្មែរនិងមេអណ្តើកបរទេសដែលដើរទាក់ទងស្រីក្មេងៗ ដោយឃាត់ខ្លួនធ្វើសំណុំរឿងឡើងតុលាការ ធ្វើទោសតាមច្បាប់។

៣. សូមព្រះសង្ឃព្រះពុទ្ធសាសនាជួយពន្យល់ពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗ ក្នុងរាជាណាចក្រកម្ពុជាទាំងមូលឲ្យយល់អំពីវិធីបោកប្រាស់របស់ជនបរទេសខិលខូចទាំងនោះនិងល្បិចរបស់មេអណ្តើកក្នុងការយកកូនស្រីអ្នកស្រុកទៅឲ្យជនបរទេសនិងឲ្យអ្នកធំអ្នកមានអំណាចដើម្បីដុល្លា។

៤. ប្រជាពលរដ្ឋខ្មែរទូទៅ ក៏ត្រូវធ្វើសហការជាមួយរាជរដ្ឋាភិបាលខ្មែរក្នុងការកំចាត់ជំនួញផ្លូវភេទនេះ គឺបើឃើញជនណាប្រព្រឹត្តដូចនេះ ត្រូវប្រាប់អាជ្ញាធរខ្មែរភ្លាម ដើម្បីចាត់ការឲ្យទាន់ពេលវេលា។ អំពីការជួញដូរមនុស្សនេះ ពុំមែនមានកំហុសតែផ្លូវអាណាចក្រដែលកំពុងពិចារណារួមគ្នាកំចាត់ប៉ុណ្ណោះទេ ព្រះពុទ្ធសាសនាបានហាមជំនួញនេះជាដាច់ខាត ព្រោះមនុស្សជាតិមានតម្លៃដ៏ខ្ពង់ខ្ពស់មិនត្រូវបន្ថោកបន្ទាបតម្លៃរបស់មនុស្សទេ ហើយការប្រព្រឹត្តកាមគុណបែបនេះ ជាអំពើអបាយមុខនាំឲ្យវិនាស។

ឈឈឈឈឈ

# ១៥- បុណ្យនៃសេចក្តីស្រឡាញ់

បុណ្យនៃសេចក្តីស្រឡាញ់នេះ កើតឡើងនៅប្រទេសអឺរ៉ុប ពុំមែនជាវប្បធម៌របស់ខ្មែរឡើយ តើហេតុអ្វីបានជាក្នុងប្រតិទិនខ្មែរ មានចុះបុណ្យនេះជាកាលបរិច្ឆេទប្រចាំឆ្នាំ ដែលពុំមែនជាប្រពៃណីរបស់ខ្មែររហូតដល់ដាក់ឃ្លាតចាកន័យដើមរបស់គេថា **ទិវាបុណ្យសង្សារ**ថ្ងៃ១៤កុម្ភៈថែមទៀត។ ក្រសួងវប្បធម៌ខ្មែរ ដែលជាក្រសួងបង្កើតឡើងសំរាប់រក្សាការពារវប្បធម៌ខ្មែរ មិនបានយកចិត្តទុកដាក់មើលការខុសត្រូវឲ្យបានសព្វគ្រប់ បណ្តោយឲ្យវប្បធម៌របៀបនេះចូលមកប្រទេសកម្ពុជាព្រមទាំងបានទទួលស្គាល់ចុះក្នុងប្រតិទិនរបស់ជាតិទៀតផង ដែលធ្វើឲ្យយុវជននិងយុវនារីខ្មែរខ្លះ ដែលខ្វះការពិចារណាទទួលយកហើយអនុវត្តអបាយមុខ ល្បែងស្រីខុសពីន័យដើមរបស់គេថែមទៀត។ គួរតែក្រសួងវប្បធម៌ប្រាប់អ្នកសរសេរប្រតិទិនកុំឲ្យដាក់ទិវានេះនៅក្នុងប្រតិទិនក្នុងឆ្នាំតៗមកទៀត។

តាមការស្រាវជ្រាវ បុព្វហេតុដែលនាំឲ្យកើតទិវានេះ មានឯកសារនិយាយខុសគ្នា ពុំមែនជារឿងពិតតាមប្រវត្តិសាស្រ្តទេ ជារឿងព្រេងនិទាន។ មានឯកសារខ្លះថា រឿងនេះមានទំនាក់ទំនងទៅសាសនាគ្រិស្ត។ ដំណើររឿង គឺមានបុរសម្នាក់ឈ្មោះ

សាំងវ៉ាឡង់ថែន(Saint Valentine) ជាព្រះសង្ឃកាតូលិករ៉ូម៉ាំង ប្រទេសអ៊ីតាលី ត្រូវកាត់ទោសប្រហារជីវិត ដោយកំហុសប្រឆាំងនឹងអធិរាជក្លូឌីយូស(Claudius)។ អធិរាជនេះបានដាក់បញ្ជាមិនឲ្យបុរសរៀបការជាមួយនឹងស្ត្រីណាទាំងអស់ ដើម្បីទុកបុរសឲ្យមានភាពបរិសុទ្ធ សំរាប់យកទៅធ្វើជាទាហាន។ព្រះសង្ឃកាតូលិកដូចឈ្មោះខាងលើបានប្រឆាំងនឹងបទបញ្ជារបស់អធិរាជនេះ ដោយលួចរៀបការជាសម្ងាត់ ក៏ត្រូវកាត់ទោសប្រហារជីវិតនៅថ្ងៃ១៤កុម្ភៈឆ្នាំ២៦៩នៃគ.ស. គឺជាថ្ងៃនៃទិវានៃសេចក្ដីស្រឡាញ់នេះឯង។ ឯកសារបានឲ្យហេតុផលខុសគ្នាថា ទិវានេះធ្វើដើម្បីរំលឹកដល់ខួបនៃការស្លាប់របស់ព្រះសង្ឃកាតូលិកនេះ ធ្វើដើម្បីធ្វើខ្លួនឲ្យទៅជាអ្នកគ្រិស្តសាសនិកពិតប្រាកដ ធ្វើដើម្បីរក្សាប្រពៃណីក្រុមរ៉ូមបុរាណថា នៅពាក់កណ្ដាលខែកុម្ភៈជាពេលចាប់ផ្ដើមរដូវត្រជាក់។ មួយទៀត ធ្វើពិធីនេះដើម្បីនឹកដល់អាទិទេពឈ្មោះហ្វូនុស(Faunus) ដែលជាអាទិទេពកសិកម្ម។

លើកយកឯកសារខ្លះមកបញ្ជាក់អំពីបុព្វហេតុដែលនាំឲ្យគេធ្វើទិវានេះ គ្មានឃើញមូលដ្ឋានពិតប្រាកដទេ គេធ្វើទិវានេះដើម្បីប្រយោជន៍អ្វី។ ទិវានេះគ្រាន់តែជាទំនៀមទម្លាប់របស់ពួក

អឺរ៉ុប ពុំមែនជារឿងទាក់ទងជាប្រវត្តិសាស្ត្រសោះឡើយ ព្រោះសាំងវ៉ាឡង់ថែននេះ គ្មានឃើញប្រវត្តិពិតក្នុងប្រវត្តិសាស្ត្រពួកអឺរ៉ុបឡើយ។

តាមការសង្កេត រាល់ថ្ងៃ១៤កុម្ភៈដែលជាទិវានៃសេចក្តីស្រឡាញ់នេះ ប្រទេសអង់គ្លេស សហរដ្ឋអាមេរិក បារាំង កាណាដា គ្មានឃើញធ្វើពិធីនេះជាធំដុំទេ ឃើញមានខ្លះដោយជូនវត្ថុជាអនុស្សាវរីយ៍និងសរសេរសំបុត្រជូនពរដល់អ្នកជាទីគោរព និងជាទីរាប់អាន ដូចម្តាយឪពុកបងប្អូននិងមិត្តភក្តិ បើមានជូនគូសង្សារក៏មានតិចណាស់ ហើយគេមិនយកទិវានេះ ជា **ថ្ងៃរួមភេទ** ដូចជាយុវជននិងយុវនារីខ្មែរខ្លះនោះឡើយ។ ទិវានេះមិនត្រូវបានយកមកអនុវត្តជាទូទៅក្នុងចំណោមអ្នកកាន់សាសនាគ្រិស្តឡើយ ដោយមានគ្រិស្តសាសនិកជននិកាយខ្លះមិនពេញចិត្តយកមកអនុវត្តដែរ។

ព្រះពុទ្ធសាសនាបានប្រៀនប្រដៅយើងថា មុននឹងជឿអ្វីមួយមកអនុវត្ត ត្រូវពិចារណាឲ្យបានល្អិតល្អន់ ព្រោះអនុវត្តតាមជំនឿខ្លះ នាំឲ្យខូចប្រយោជន៍ខ្លួននិងប្រយោជន៍សង្គម។ យ៉ាងណាមិញ ទិវានៃសេចក្តីស្រឡាញ់ ដែលខ្មែរខ្លះយកមកក្រឡែឲ្យលើសពីគេ ឲ្យខូចពីទិវារបស់គេថា បុណ្យសង្សារ គឺជាទិវា

នៃការប្រព្រឹត្តអំពើអបាយមុខ នាំឲ្យខូចប្រយោជន៍សង្គមធ្ងន់ណាស់។ ខូចប្រយោជន៍ គឺពេលទិវានេះមកដល់យុវជននិងយុវនារីខ្មែរខ្លះជ្រួលជ្រើម ដូច**មមាចចូលឆ្នើង**។ ដើរកាត់ជួបគ្នាមានខ្លះហ៊ានប្រព្រឹត្តអំពើកាមគុណថែមទៀត កន្លងប្រពៃណីរបស់ជាតិខ្លួន គេចមិនព្រមទៅសាលារៀន ដែលជាវ័យសំអាតខ្លួនដើម្បីសិក្សាយកចំណេះ កសាងខ្លួន កសាងគ្រួសារ កសាងសង្គមរបស់ខ្លួន។ អបាយមុខ ល្បែងស្រី ល្បែងស្រា ល្បែងស៊ីសង ពិតជាធ្វើឲ្យអ្នកប្រព្រឹត្តវិនាសប្រាកដណាស់ គឺកើតចោរលួចចោរប្លន់ កើតអំពើហឹង្សាគ្រប់យ៉ាង។ កុំប្រើពាក្យថាបុណ្យព្រោះពាក្យបុណ្យជាការស្ងប់ផ្លូវចិត្ត ពុំមាន**រាគៈទោសៈមោហៈ** បើប្រព្រឹត្តអបាយមុខ ឈ្មោះថាទិវាប្រព្រឹត្តធ្វើអំពើបាបទៅវិញ។

ដើម្បីឲ្យទៅជាយុវជននិងយុវនារីល្អ ត្រូវផ្អែកលើកត្តាពីរយ៉ាង គឺវិជ្ជាសម្បត្តិ និងចរិយាសម្បត្តិ គឺត្រូវសិក្សាឲ្យបានជ្រៅជ្រះនិងការប្រព្រឹត្តឲ្យបានល្អត្រឹមត្រូវ មិនដើរលេងពាលាអាវ៉ាសែប្រព្រឹត្តអបាយមុខផ្សេងៗ ស្គាល់បាបស្គាល់បុណ្យស្គាល់គុណស្គាល់ទោសជាដើម។ ទិវានៃសេចក្តីស្រឡាញ់ ដែលក្លាយមកជាទិវាបុណ្យស្នេហានេះ ត្រូវកុំឲ្យកើតមានក្នុងសង្គមកម្ពុជា ព្រោះជាពិសពុលរបស់សង្គមខ្មែរ។ កុំដាក់ទិវានេះក្នុង

ប្រតិទិនប្រចាំឆ្នាំ។ ក្រសួងវប្បធម៌គប្បីយកចិត្តទុកដាក់ឲ្យខ្លាំង ចំពោះវប្បធម៌បរទេសហូរចូលមកប្រទេសកម្ពុជា។

ឈឈឈឈឈ

# ១៦- ស្ត្រីម្នាក់បានស្លាប់ទាំងទារកក្នុងផ្ទៃ

តាមរបាយការណ៍ពត៌មានពីប្រទេសកម្ពុជាថា ស្ត្រីខ្មែរម្នាក់ឈ្មោះ **ម៉មយឿប** អាយុ៣៧ឆ្នាំ បានស្លាប់ទាំងទារកនៅក្នុងផ្ទៃនៅក្នុងមន្ទីរពេទ្យមួយនៅខេត្តប៉ៃលិន ព្រោះគ្មានប្រាក់១០ម៉ឺនរៀលបង់ឲ្យពេទ្យ។ នៅកម្ពុជាបច្ចុប្បន្ន ពលរដ្ឋខ្មែរជាច្រើនជាអ្នកក្រីក្រ បើគ្មានប្រាក់ឲ្យមន្ទីរពេទ្យឬគ្រូពេទ្យទេ នោះអ្នកជម្ងឺមិនត្រូវបានយកចិត្តទុកដាក់ព្យាបាលឡើយ។ លោក **ម៉ុតរ៉ែន** អាយុ៤៨ឆ្នាំជាស្វាមីអ្នករងគ្រោះ នៅភូមិអំពៅឡិច សង្កាត់ប៉ៃលិន ស្រុកនិងខេត្តប៉ៃលិន បាននាំភរិយាដូចឈ្មោះខាងលើដែលឈឺពោះសម្រាលកូន ទៅមន្ទីរពេទ្យមួយទីក្រុងប៉ៃលិនក្នុងភាពអាសន្ន ដោយពេទ្យស្រុកមិនអាចធ្វើឲ្យសម្រាលតាមប្រក្រតីបាន។ ស្វាមីនិងភរិយាបានទៅដល់មន្ទីរពេទ្យក្រុងប៉ៃលិនម៉ោង១១យប់នៃថ្ងៃ១៥កុម្ភៈ២០០៩។ ពេលទៅដល់ អ្នកយាមក្នុងមន្ទីរពេទ្យមិនបានចាត់ចែងពិនិត្យមើលឲ្យទាន់ពេលវេលាទេ បែរជានិយាយឲ្យបង់ថ្លៃព្យាបាល១០ម៉ឺនសិន ទើបចាត់ចែងពិនិត្យមើលអ្នកជម្ងឺសម្រាលកូននោះ។ ទាំងប្តីទាំងភរិយាដែលកំពុងឈឺពោះស្ទើរតែដាច់ខ្យល់ អង្វរពេទ្យឲ្យជួយសង្គ្រោះឲ្យបានឆាប់ ខ្ញុំគ្មានប្រាក់បង់សេវាពេទ្យទេ។ តាមអាជ្ញាធរភូមិថា

គ្រួសារអ្នករងគ្រោះ មានជីវភាពក្រីក្រខ្លាំងណាស់ មានកូនរហូតដល់៧នាក់ ហើយកូននៅក្នុងផ្ទៃនេះជាកូនទី៨ ហើយផ្ទះរបស់គាត់ត្រូវខ្យល់ព្យុះបោកបក់បើុងដំបូលខ្ទេចខ្ទីថែមទៀត។ ទោះបីអ្នកជម្ងឺស្រែកឲ្យជួយសង្គ្រោះយ៉ាងណា ក៏គ្មានបានផលអ្វីឡើយ ក្រុមគ្រូពេទ្យនាំគ្នាចូលបន្ទប់ដេក ទុកអ្នកជម្ងឺឲ្យអង្គុយនៅបរិវេណខាងក្រៅ រងចាំរហូតដល់អ្នកជម្ងឺកាន់តែឈឺធ្ងន់ ប្ដីទៅហៅពេទ្យរហូត៣ដង បានសុំអង្វរករគ្រូពេទ្យជាបន្តបន្ទាប់ឲ្យជួយសង្គ្រោះ ទោះបីវះកាត់ក៏ដោយ ឲ្យតែក្រុមគ្រូពេទ្យជួយ។ ស្ត្រីអ្នកជម្ងឺអង្វរថា ពូជួយខ្ញុំផង បើមិនវះ ខ្ញុំមិនរស់ទេ។ ពេទ្យគ្មានចម្លើយអ្វីសោះ ដើរចុះដើរឡើងរហូតដល់អ្នកជម្ងឺស្លាប់នៅម៉ោង៥ភ្លឺ ជាមួយកូនក្នុងផ្ទៃ នៃថ្ងៃ១៦កុម្ភៈ២០០៩។ អ្នកជម្ងឺដែលត្រូវសង្គ្រោះជាបន្ទាន់ គ្រូពេទ្យបានទុកចោល៦ម៉ោង គឺពីម៉ោង១១យប់ដល់ម៉ោង៥ភ្លឺ រហូតដល់អ្នកជម្ងឺស្លាប់ ដោយខ្វះករុណាធម៌ យកប្រាក់ជាធំ គួរឲ្យសង្វេគណាស់។

ក្រោយពីមរណភាព ត្រូវរថយន្តមន្ទីរពេទ្យដឹកយកទៅបូជានៅវត្តរតនសោភណ ហៅវត្តកោងកាង ជាប់ជើងភ្នំយ៉ាត ចម្ងាយ១គ.ម. ពីមន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន។ សាកសពនោះមិនត្រូវបានសមត្ថកិច្ចនគរបាលទៅត្រួតពិនិត្យឡើយ ឬក៏ឲ្យ

វេជ្ជបណ្ឌិតឯករាជ្យធ្វើកោសល្លវិច័យ មុននឹងយកទៅបូជា និងមិនបានអនុញ្ញាតពីប្ដីរបស់អ្នកជម្ងឺផង។ ហេតុអ្វីបានជាគ្រូពេទ្យប្រញាប់ប្រញាល់យកសាកសពទៅបូជា តើមានអាថ៌កំបាំងអ្វីចំពោះការស្លាប់របស់ស្ត្រីឆ្លងទន្លេនេះ? លោក **សៅ សឿន** ប្រធានគណៈគ្រូពេទ្យប្រចាំខេត្តបាត់ដំបងមានប្រសាសន៍ថា ករណីបែបនេះមានកើតមានជាច្រើនទូទាំងខេត្តក្រុងនៃប្រទេសកម្ពុជា ប៉ុន្តែពត៌មានទាំងនោះ ត្រូវបានគេលាក់មិនរាយការណ៍ លោកបន្តថា ករណីម្ដាយនិងកូនស្លាប់ គឺដោយសារគ្រូពេទ្យគិតលុយជាធំ ហើយបោះបង់ចោលក្រមសីលធម៌ដែលខ្លួនត្រូវប្រតិបត្តិ កំហុសពេទ្យ ពុំមែនកំហុសអ្នកជម្ងឺមករកសេវាព្យាបាលទេ គេមិនព្រមព្យាបាល គិតគូរតែរឿងលុយកាក់ ខុសក្រមសីលធម៌ច្បាស់ណាស់។ យោលតាមអនុក្រិត្យស្ដីពីក្រមសីលធម៌គ្រូពេទ្យ ដែលទីស្ដីការគណៈរដ្ឋមន្ត្រី អនុម័តិកាលពីឆ្នាំ២០០៣ ត្រង់មាត្រា២ចែងថា គ្រូពេទ្យត្រូវតែគោរពជីវិតរាងកាយនិងសេចក្ដីថ្លៃថ្នូររបស់មនុស្ស។ ដូច្នេះ គ្រូពេទ្យពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាគ្រូពេទ្យ ទើបបណ្ដាលឲ្យស្ត្រីជាម្ដាយនិងទារកស្លាប់នៅក្នុងផ្ទៃ។ តាមរបាយការណ៍ខ្លះថា មានគ្រូពេទ្យ៤នាក់រួមទាំងអនុប្រធានគ្រូពេទ្យផងបានមកជួយ

សង្គ្រោះដែរ តែវាហួសពេលទៅហើយ ដោយសារឈាមចេញច្រើនពេក នាងក៏បានស្លាប់នៅម៉ោង៥ភ្លឺទៅ។

ការឆ្លងទន្លេនៅប្រទេសជឿនលឿនមិនដែលមានគ្រោះថ្នាក់រហូតដល់ស្លាប់ទេ។ គេតែងតែសម្រាលកូននៅមន្ទីរពេទ្យ បើមិនអាចសម្រាលតាមប្រក្រតីទេ គេចាប់វះយកកូនភ្លាមៗ មិនដែលមានគ្រោះថ្នាក់ទេ ម្ដាយនិងទារកសង្គ្រោះរស់ទាំងពីរ។ តាមច្បាប់នៅប្រទេសជឿនលឿន រាល់អ្នកជម្ងឺធ្ងន់ដែលត្រូវសង្គ្រោះជាបន្ទាន់ គ្រូពេទ្យត្រូវតែប្រញាប់ប្រញាល់សង្គ្រោះភ្លាម ទោះបីអ្នកខ្លះមិនមានសំបុត្រធានា (Assurance maladie, health care) ក៏ដោយ។ សង្គ្រោះរួចហើយ ទើបគិតគូរបញ្ហានោះជាក្រោយ។ បើមិនបានជួយសង្គ្រោះទេ ទុកឲ្យអ្នកជម្ងឺដែលត្រូវសង្គ្រោះជាបន្ទាន់ស្លាប់ នឹងត្រូវមានទោសតាមច្បាប់។ សូម្បីតែឈ្លើយសឹក ដែលគេចាប់បានក្នុងសម័យសង្គ្រាម ក៏ត្រូវយកមកសង្គ្រោះដែរបើមានជម្ងឺឬត្រូវរបួស ទើបធ្វើតាមច្បាប់ជាក្រោយ។ ព្រះពុទ្ធសាសនា ត្រង់ករុណាធម៌ក្នុងព្រហ្មវិហារធម៌ពោលថា បុគ្គលត្រូវមានការអាណិតអាសូរចំពោះមនុស្សសត្វដែលមានទុក្ខ ហើយគប្បីជួយសង្គ្រោះ។ ការជួយសង្គ្រោះអ្នកមានទុក្ខជាបុណ្យកុសលខ្ពង់ខ្ពស់ណាស់។ ដើ

ម្បីការពារកុំឲ្យមានស្លាប់ដោយការធ្វេសប្រហែសរបស់គ្រូពេទ្យ ដូចករណីអ្នកស្រី **ទ័មយៀប** កុំឲ្យកើតមានតទៅទៀត គប្បីរាជរដ្ឋាភិបាលនិងក្រសួងសុខាភិបាលចាត់វិធានការយ៉ាងណាឲ្យដឹងច្បាស់ថា អ្នកក្រព្យាបាលមិនយកប្រាក់ ហើយអប់រំក្រមសីលធម៌ដល់គ្រូពេទ្យទាំងអស់ទូទាំងប្រទេសកម្ពុជាផង។ មួយទៀត គួរអាណិតអាសូរដល់គ្រូពេទ្យចំពោះបុគ្គលិកធម្មតាមានប្រាក់ខែទាបបានតែ៣៥ដុល្លាក្នុងមួយខែ គួរពិចារណាដំឡើងឲ្យមានជីវភាពសមរម្យផង។

ឈឈឈឈឈ

# ១៧- វាសនានៃស្ត្រីកម្មកររោងចក្រខ្មែរ

បន្ទាប់ពីបញ្ចប់សង្គ្រាមក្នុងស្រុកមក ប្រជាពលរដ្ឋខ្មែរបានផ្ដើមជីវភាពឡើងវិញ។ ដោយសារការបើកផ្សារសេរី មានអ្នកវិនិយោគទុន ក៏មកបង្កើតរោងចក្រ ជាពិសេសរោងចក្រធ្វើសំលៀកបំពាក់។ រោងចក្រទាំងនេះ បានទទួលស្ត្រីខ្មែរចំនួនប្រហែល៣សែននាក់ឲ្យចូលធ្វើជាកម្មករ។ ដូច្នេះ រោងចក្របានជួយឲ្យខ្មែរមានការធ្វើរាប់សែននាក់។ ឥឡូវនេះ ដោយសារមានវិបត្តិសេដ្ឋកិច្ចពិភពលោក រោងចក្រខ្លះបានត្រូវបិទ ធ្វើឲ្យស្រីកម្មករខ្មែរអត់ការងារធ្វើរាប់ម៉ឺននាក់ ទោះបីមានបើករោងចក្រថ្មីៗខ្លះទៀតក៏ដោយ។ តើស្ត្រីខ្មែរដែលអត់ការងារធ្វើទាំងនោះងាកទៅរកការងារអ្វីធ្វើ?

ការងារមានច្រើនយ៉ាង ចំពោះព្រះពុទ្ធសាសនាបានហាមការងារណាដែលមិនប្រកបដោយធម៌ ដូចជាការជួញដូរមនុស្ស ជួញគ្រឿងសាស្ត្រាវុធ ជួញគ្រឿងញៀន គ្រឿងស្រវឹង ជួញថ្នាំពិស និងជំនួញខ្លះទៀត ដែលជាមុខរបរចាត់ចូលក្នុងអបាយមុខ គឺមុខរបរធ្វើជាស្រីពេស្យាចារ។ មុខរបរស្រីពេស្យាចារនេះតាមផ្លូវអាណាចក្រ ក៏សង្គមមនុស្សមិនឲ្យតម្លៃដែរ។ ប្រទេសភាគច្រើនក្នុងលោក មិនដាក់មុខរបរនេះឲ្យស្របច្បាប់ឡើយ។

តាមធម្មតា មុខរបរនេះគេត្រូវការតែវ័យក្មេង លុះដល់ពេលមានចំណាស់បន្តិច គេឈប់ត្រូវការហើយ។ ជាលទ្ធផល អ្នកប្រកបមុខរបរនេះអាចកើតរោគអេដជារោគគ្មានថ្នាំព្យាបាលឲ្យជាឡើយ។ ដូច្នេះ ស្ត្រីនោះត្រូវពិការរហូតបាត់បង់ជីវិត។ មុខរបរដែលមិនស្របច្បាប់ ផ្លូវចិត្តតែងតែមានភ័យខ្លាចជានិច្ច ជាមុខរបរលួចលាក់ ហើយតែងមានការប្រមាថពីបុរសដើម្បីបង្ខំធ្វើតាមបំណងរបស់ខ្លួន។ មិនតែប៉ុណ្ណោះ មេបនដែលគ្មានធម៌មេត្តា តែងតែកេងប្រវញ្ច័និងធ្វើបាបស្ត្រីបំរើផ្លូវភេទផង។

ទំនៀមទម្លាប់ខ្មែរខាងផ្លូវភេទនេះ មានការលាក់លៀមនិងតឹងតែងណាស់។ កុមារីខ្មែរមានវ័យជំទង់ ម្តាយឪពុកតែងតែការពារមិនបណ្តោយឲ្យដើរតែពីរនាក់ជាមួយបុរសណាឡើយ។ ពេលធំពេញរូបរាងជំនាន់ដើមតែងតែធ្វើពិធីមួយ ហៅថាពិធីចូលម្លប់។ ពិធីនេះ មានគោលសំខាន់គឺការអប់រំចិត្ត ពុំមែនបន្ទុំពណ៌សម្បុរឲ្យស្អាតដូចអ្នកខ្លះយល់នោះឡើយ។ ចាស់ពីបូរាណឆ្លាតណាស់ ពេលកូនស្រីគ្រប់ការហើយត្រូវតែប្រយ័ត្នព្រោះវ័យនេះ បើមិនបានអប់រំចិត្តឲ្យល្អទេ អាចភ្លើតភ្លើនក្នុងផ្លូវកាមគុណកន្លងប្រពៃណី។ ក៏ដូចគ្នានឹងកូនប្រុសជំទង់ឲ្យទៅនៅវត្តឲ្យបួសជាសាមណេរជាភិក្ខុ ក៏ដើម្បីអប់រំចិត្តឲ្យមាន

ចរិយាល្អដូចកូនស្រីដែរ។ ចរិយាកូនប្រុសកូនស្រីខ្មែរសម័យដើម មិនដែលខូចកាចនឹងគ្នាឡើយ បើយូរៗមានមួយ ម្ដាយឪពុកមានការខ្មាសគេណាស់ មានខ្លះមិនហ៊ាននៅក្នុងភូមិនោះផង បានផ្លាស់ទៅនៅខេត្តដទៃទៀត។ ខ្មែរឲ្យតម្លៃទៅលើកិត្តិយស ទោះបីអស់ទ្រព្យអស់សម្បត្តិក៏ដោយ កុំឲ្យតែខូចកិត្តិយសកេរ្តិ៍ឈ្មោះ។ ស្វាមីភរិយាខ្មែរដែលបានគ្នាជាប្ដីប្រពន្ធដោយម្ដាយទុកឪពុកដាក់មិនសូវឃើញលែងលះគ្នាឡើយ ឃើញតែរស់នៅជាមួយគ្នារហូតចាស់ជរា។ វប្បធម៌ខ្មែរដ៏ល្អនេះ បានត្រូវប្រទេសនៅអឺរ៉ុបកោតសរសើយ៉ាងខ្លាំង។

ចំពោះកូនចៅស្រីកម្មករខ្មែរ ដែលអត់ការងារធ្វើ ដោយរោងចក្របានបិទទ្វារ ត្រូវរកការងារធ្វើកន្លែងផ្សេងទៀត។ គួររកការងារណាដែលឥតទោស ការងារដែលសង្គមឲ្យតម្លៃ។ កុំឲ្យធ្លាក់ទៅលើការងារស្រីពេស្យា តាមការអូសទាញរបស់ឈ្មួញទុច្ចរិតនិងជនខិលខូចឲ្យសោះ។ ដូចបានពោលមកហើយ មុខរបរស្រីពេស្យានេះជាមុខរបរមិនស្ថិតស្ថេរ សង្គមមិនឲ្យតម្លៃ អាចខូចសុខភាពអស់មួយជីវិត។ ប្រទេសកម្ពុជាជាប្រទេសកសិកម្មចំនួនជាង៨០ភាគរយ ពីដើមឪពុកម្នាក់អាចចិញ្ចឹមកូនប្អូនដប់នាក់ឲ្យរស់បានដោយការធ្វើស្រែចំការនេះ

ឯង។ បើរកការងារធ្វើដ៏ត្រឹមត្រូវនៅទីក្រុងមិនបានទេ កូនចៅគួរត្រឡប់ទៅធ្វើការងារកសិកម្មទៅភូមិកំណើតវិញ ជាការប្រសើរបំផុត កុំប្រកបមុខរបរណាដែលនាំឲ្យខូចកិត្តិយសខ្លួននិងខូចកិត្តិយសគ្រួសារ។ ការកើតមកជាមនុស្សទោះជាបុរសក្តីស្រីក្តីមានតម្លៃណាស់ កុំធ្វើឲ្យតម្លៃខ្លួនថោកទាប។ ការកើតមកជាមនុស្សពេញលក្ខណៈជាការក្រ។ យ៉ាងណាមិញ បណ្តាស្ត្រីទាំងឡាយក្នុងប្រទេសនៅអាស៊ីភាគអគ្នេយ៍ គេសរសើរស្ត្រីខ្មែរថាមានចរិយាល្អ គោរពស្វាមី គោរពមាតាបិតា ហើយគេកម្រឃើញភរិយាក្បត់ចិត្តពីស្វាមីណាស់ មានតែបុរសខ្មែរទេ ដែលមានខ្លះក្បត់ចិត្តពីភរិយារបស់ខ្លួនទៅរកស្ត្រីដទៃទៀត។ គេសង្កេតឃើញទៀតថា ស្ត្រីខ្មែរពុំសូវយកបុរសបរទេសជាប្តីរបស់ខ្លួនឡើយ។ ដូច្នេះ កូនចៅកម្មករស្ត្រីខ្មែរ បើបាត់បង់ការងារក្នុងរោងចក្រហើយ កុំជឿការអូសទាញពីជនទុច្ចរិតឲ្យទៅប្រកបមុខរបរអបាយមុខ គឺមុខរបរពេស្យាចារឬទៅរកស៊ីនៅបរទេស គួរត្រឡប់មកជួបម្តាយឪពុកនៅភូមិកំណើតវិញ គួរការពារកិត្តិយសមាតាបិតា កុំឲ្យគាត់បាក់មុខបាក់មាត់ ធ្វើខ្លួនឲ្យទៅជាស្ត្រីរតនៈ ជាមាតានៃពិភពលោក។

៚៚៚